**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ភាពមិនគ្រប់គ្រាន់នៃប្រាក់ខែរបស់កម្មករនិយោជិត

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. សុខ ទេសកញ្ញៈនា**

**ក. លី ស៊ិនម៉ូនីតា**

សាស្ត្រាចារ្យណែនាំ

លោក **ឡឹក ពិដោរ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ភាពមិនគ្រប់គ្រាន់នៃប្រាក់ខែរបស់កម្មករនិយោជិត

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភាឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **សុខទេសកញ្ញៈនា**
**លី ស៊ិនម៉ូនីតា**

សាស្ត្រាចារ្យណែនាំ
លោក **ឡឹក ពិដោរ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំ **សុខ ទេសកញ្ញ:នា** និង **លី ស៊ិនម៉ូនីតា** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ ដែលសិក្សាចាប់ពីឆ្នាំ២០១៥-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ

យើងខ្ញុំទាំងពីររូប សូមគោរពដឹងគុណចំពោះលោកឪពុក និងអ្នកម្ដាយរបស់យើងខ្ញុំទាំងពីររូប ដែលបានផ្ដល់កំណើត និង យកចិត្តទុកដាក់ចិញ្ចឹមបីបាច់ ថែរក្សា អប់រំទូន្មានកូនទាំងពីចាប់កំណើត រហូតមកដល់ធំដឹងក្ដី ព្រមទាំងជួយជ្រោមជ្រែងគ្រប់បែបយ៉ាង ទាំងផ្នែកស្មារតី និងសម្ភារៈដោយមិនដែលត្អូញត្អែរ និងរអ៊ូរទាំឡើយ ហើយសុខចិត្តស៊ូលំបាកខ្លួនឯងធ្វើយ៉ាងណាឲ្យកូនមានលទ្ធភាពចូលសិក្សារៀនសូត្រ តាំងពីថ្នាក់បឋមសិក្សា រហូតដល់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រថ្វី ត្បិតកូនជាបន្ទុកដ៏ធំរបស់លោកទាំងពីរក៏ដោយ។

ឯកឧត្ដមសាកលវិទ្យាធិការ លុយ បណ្ណា សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់ឱកាសឲ្យយើងខ្ញុំទាំងពីរ កសាងសមត្ថភាព និង ចំណេះដឹង តាមរយៈការសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរ។

ជាពិសេស លោកសាស្ត្រាចារ្យ **ឌៀក ពិដោរ** ជាសាស្ត្រាចារ្យណែនាំ ដែលលោកបានយកចិត្តទុកដាក់ពន្យល់ណែនាំយើងទាំងពីរ និងចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃដើម្បីចង្អុលបង្ហាញពីរបៀបតាក់តែង និងពន្យល់ណែនាំយើងខ្ញុំទាំងពីរឲ្យបានយល់ពីប្រធានបទ។ ការពន្យល់ពីចំណុចខ្វះខាតរបស់លោក និងកែប្រែកំហុសខុសឆ្គងរបស់យើងខ្ញុំ គឺជាស្ពានមួយសម្រាប់បំភ្លឺផ្លូវឲ្យយើងខ្ញុំទាំងពីរឈានទៅសម្រេចបាននូវគោលដៅជាស្ថាពរ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរ សូមលើកដៃបួងសួងដល់ទេវតា និងវត្ថុស័ក្ដសិទ្ធក្នុងលោកប្រទានពរជ័យ សិរីមង្គល ដល់លោកអ្នកមានគុណនៃយើងខ្ញុំទាំងពីរ ឯកឧត្ដមសាកលវិទ្យាធិការ លោកសាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សូមឲ្យទទួលបាននូវសុខភាពល្អ ប្រាជ្ញាវៀងវៃ ទទួលជោគជ័យគ្រប់ភារកិច្ច ជាពិសេសជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ស្ថិតក្នុងស្ថានភាពជានិស្សិត ដែលកំពុងសិក្សាលើមុខជំនាញច្បាប់ ក្នុងកម្រិតបរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ ខ្ញុំមានសេចក្តីត្រេកអរជាខ្លាំង ដែលបានទទួលកិត្តិយស បានក្លាយជានិស្សិតសរសេរសារណា ក្នុងចំណោមនិស្សិតដទៃ។ យើងខ្ញុំ បានសម្រេចជ្រើសរើសជំនាញនីតិឯកជន ក្នុងការសរសេរសារណានេះ ដោយសម្រេចយកជំនាញ ជាក់លាក់មួយ គឺនីតិការងារ ក្រោមប្រធានបទ "ភាពមិនគ្រប់គ្រាន់នៃប្រាក់ខែរបស់កម្មករនិយោជិត" ហើយការជ្រើសរើសប្រធានបទនេះ គឺដោយសារតែចិត្តស្រលាញ់ និង ចំណេះដឹងដែលធ្លាប់សិក្សា នៅក្នុងថ្នាក់។ ក្រៅពីមូលហេតុទាំងពីរខាងលើនេះហើយ ចំណុចសំខាន់ដែលធ្វើឲ្យយើងខ្ញុំជ្រើស រើសប្រធានបទនេះ គឺដោយសារតែស្ថានភាពសង្គមជាក់ស្តែងដែលយើងខ្ញុំបានប្រទះឃើញសព្វថ្ងៃ ទាក់ទិននឹងកង្វះខាតប្រាក់ខែរបស់កម្មករនិយោជិត ដែលឈានទៅដល់ការធ្វើបាតុកម្មទាមទារ តម្លើងប្រាក់ខែពីសំណាក់នយោជក។ ម្យ៉ាងទៀត ដោយសារតែឃើញនូវស្ថានភាពក្នុងសង្គមបែប នេះហើយ ទើបយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវអំពីប្រធានបទនេះ ក្នុងគោលបំណងស្វែងយល់ អំពីប្រភេទនៃប្រាក់ខែ របៀបនៃការកំណត់ប្រាក់ខែ មូលហេតុដែលធ្វើឲ្យមានភាពមិនគ្រប់គ្រាន់នៃ ប្រាក់ខែ ព្រមទាំងដំណោះស្រាយក្នុងការដោះស្រាយភាពមិនខ្វះខាតនេះ។

នេះជាសមិទ្ធិផលរបស់យើងខ្ញុំក្នុងការសិក្សាស្រាវជ្រាវកន្លងមក ដោយទទួលបានការ បណ្តុះបណ្តាលពីសំណាក់លោកគ្រូសាស្ត្រាចារ្យណែនាំ ព្រមទាំងចំណេះដឹងដែលធ្លាប់សិក្សាកន្លងមកជាមួយលោកសាស្ត្រាចារ្យក្នុងសាលា ហើយដែលធ្វើឲ្យយើងខ្ញុំឈានទៅដល់ការសម្រេចជោគ ជ័យនៅក្នុងការស្រាវជ្រាវធ្វើសារណានេះ។ យើងខ្ញុំក៏សូមអភ័យទោសទុកជាមុនចំពោះកំហុសទាំង ឡាយ ដែលកើតមានឡើងដោយអចេតនា ហើយខ្ញុំស្វាគមន៍រាល់មតិរិះគន់ក្នុងន័យស្ថាបនាពី សំណាក់មិត្តនិស្សិតអ្នកអានទាំងឡាយដើម្បីទុកជាមេរៀន និង បទពិសោធន៍ សម្រាប់អភិវឌ្ឍន៍ខ្លួន ទៅថ្ងៃក្រោយ។ ជាចុងបញ្ចប់ ខ្ញុំសង្ឃឹមថាប្រធានបទនេះនឹងផ្តល់នូវចំណេះដឹងបន្ថែមទៀត ដើម្បី ឲ្យអ្នកអានយល់បានកាន់តែច្បាស់ទាក់ទិននឹងការអនុវត្តលើប្រាក់ឈ្នួលនេះ។

# មាតិកា

**សេចក្តីផ្តើម** ..... ១

**ជំពូកទី១៖ មូលដ្ឋាននៃការកំណត់ប្រាក់ខែ** ..... ៤

**ផ្នែកទី១ សញ្ញាណនៃប្រាក់ឈ្នួល** ..... ៤

១.១. ប្រាក់ឈ្នួលសុទ្ធសាធ ..... ៤

១.១.១ ប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលថ្ងៃ ..... ៤

១.១.២ ប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលយប់ ..... ៥

១.១.៣ ប្រាក់ឈ្នួលទាបបំផុត ..... ៥

១.១.៤ សិទ្ធិក្នុងការកំណត់ប្រាក់ឈ្នួលតាមអនុសញ្ញារួម ..... ៦

១.១.៥ ប្រាក់ឈ្នួលជារូបិយវត្ថុ ..... ៦

១.១.៦ ប្រាក់ឈ្នួលជារូបិយប័ណ្ណ ..... ៧

១.២ ប្រភេទនៃប្រាក់ឈ្នួល ..... ៧

១.២.១ ប្រាក់ឈ្នួលសម្រាប់ការងារថែមម៉ោង ..... ៨

ក. ប្រាក់ឈ្នួលបន្ថែមម៉ោងចំពោះការងារពេលថ្ងៃ ..... ៩

ខ. ប្រាក់ឈ្នួលបន្ថែមម៉ោងចំពោះការងារពេលយប់ ..... ៩

គ. ប្រាក់បន្ថែមម៉ោងសម្រាប់ថ្ងៃឈប់សម្រាកចុងសប្តាហ៍ ..... ៩

ឃ. ប្រាក់ថ្លៃបាយសម្រាប់ការងារបន្ថែមម៉ោង ..... ១០

១.២.២ ប្រាក់ឈ្នួលតាមឋានានុក្រមការងារ ..... ១០

ក. កូនជាង ..... ១០

ខ. ការងារសាកល្បង ..... ១០

គ. កម្មករពេញសិទ្ធិ ..... ១១

១.២.៣ ប្រាក់ផ្សេងៗគិតបញ្ចូលក្នុងប្រាក់ឈ្នួល ..... ១១

ក.ប្រាក់បុព្វលាភ ..... ១១

ខ. ប្រាក់បំណាច់ ........................................................................................... ១១

ខ.១. ប្រាក់បំណាច់បណ្តេញចេញ ........................................................................ ១២

ខ.២. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ............................................................ ១២

ខ.៣. ប្រាក់ទូទាត់ចំពោះការមិនជូនដំណឹង............................................................ ១៣

១.២.៤ ប្រាក់ជម្ងឺចិត្ត (កិច្ចសន្យាការងារមានថិរវេលាកំណត់) .......................................... ១៤

១.២.៥ ប្រាក់ជម្ងឺចិត្ត (កិច្ចសន្យាការងារមានថិរវេលាមិនកំណត់).................................... ១៤

១.២.៦ ប្រាក់វិភាជន៍សម្រាប់ឈប់សម្រាក.................................................................... ១៥

ក. វិភាជន៍សម្រាប់ការឈប់សម្រាកថ្ងៃបុណ្យ ............................................................ ១៥

ខ. ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល..................................................... ១៦

គ. ការឈប់សម្រាកពីរថ្ងៃក្នុង ១សប្តាហ៍ដែលមានប្រាក់ឈ្នួល ................................. ១៧

ឃ. ការឈប់សម្រាកពិសេសដែលមានប្រាក់ឈ្នួល ................................................. ១៧

១.២.៧ ប្រាក់កំរៃជើងសា ....................................................................................... ១៨

១.២.៨ ប្រាក់ធានានុគ្រោះ ........................................................................................ ១៨

១.២.៩ ប្រាក់ដែលមានតម្លៃអត្ថប្រយោជន៍ជាវត្ថុ............................................................ ១៩

១.២.១០ ភាគកម្មក្នុងប្រាក់ចំណេញ ........................................................................... ១៩

១.២.១១ ប្រាក់រង្វាន់ ............................................................................................... ១៩

ក.ប្រាក់រង្វាន់សម្រាប់ការងារទៀងទាត់ .................................................................. ១៩

ខ. ប្រាក់រង្វាន់អតីតភាព ........................................................................................ ១៩

១.២.១២ ប្រាក់វិភាជន៍គ្រួសារដែលលើសពីច្បាប់តម្រូវ ..................................................២១

**ផ្នែកទី២ ប្រព័ន្ធកំណត់ប្រាក់ខែ** ..........................................................................២១

**២.១. កត្តាសង្គម**.........................................................................................................២១

**២.២. កត្តាសេដ្ឋកិច្ច**.....................................................................................................២២

**ជំពូកទី២៖ នយោបាយប្រាក់ខែ** ........ ២៣
**ផ្នែកទី១ ការវិវត្តនៃប្រាក់ឈ្នួលពីឆ្នាំ ១៩៩៧ ដល់បច្ចុប្បន្នជាតួលេខ** ........ ២៣
**ផ្នែកទី២ វិធីនៃការកំណត់ប្រាក់ខែដែលត្រូវគោរព** ........ ២៨
២.១. វិធានដែលទាក់ទងទៅនឹងប្រាក់ខែអប្បបរមា ........ ២៨
២.២. គោលការណ៍សមភាពនៃលាភការណ៍រវាងស្ត្រី និងបុរស ........ ២៨
២.៣. ការមិនរើសអើង(ជាអាទ៍សហាជីព) ........ ២៩
**ផ្នែកទី៣ លក្ខណៈវិនិច្ឆ័យដែលជាមូលដ្ឋានក្នុងការបង្កើតនយោបាយប្រាក់ខែ** ........ ២៩
៣.១. លក្ខណៈវិនិច្ឆ័យសង្គម ........ ២៩
៣.១.១ និយមន័យនៃតម្រូវការ ........ ៣១
៣.១.២ ការវាយតម្លៃនៃតម្រូវការ ........ ៣១
៣.២. លក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ច ........ ៣២
៣.២.១ ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា ........ ៣២
៣.២.២ មូលហេតុដែលធ្វើឲ្យប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាទាបជាងប្រទេសដទៃ ........ ៣៣
ក. កត្តាសុខភាព ........ ៣៤
ខ. កត្តាការសិក្សា ........ ៣៤
គ. កត្តាវិសមភាពក្នុងសង្គម ........ ៣៥
ឃ. កត្តាសន្តិសុខសង្គម ........ ៣៥
ង. កត្តាការជួញដូរ និង លំហូរហិរញ្ញវត្ថុ ........ ៣៦
ច. និរន្តរភាពសេដ្ឋកិច្ចសង្គម ........ ៣៦
**សេចក្តីសន្និដ្ឋាន** ........ ៣៨
**អនុសាសន៍** ........ ៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើនដែលជាប្រទេសកំពុងអភិវឌ្ឍន៍។ វិស័យដែលរួមចំណែកធ្វើឲ្យប្រទេសកម្ពុជាមានការរីកចម្រើនច្រើនគឺមានវិស័យវាយនភណ្ឌ កាត់ដេរ សម្លៀកបំពាក់ និង ផលិតស្បែកជើង ដោយទទួលបានការដាក់ទុនវិនិយោគពីសំណាក់អ្នកវិនិយោគទុនបរទេសជាច្រើន ហើយតាមរយៈការវិនិយោគទាំងនេះជាប្រការដែលនាំឲ្យមានការផ្តល់ការងារដល់ប្រជាជនកម្ពុជា។ ដូចនេះ ប្រាក់ឈ្នួលការងារមានសារៈសំខាន់ណាស់នៅក្នុងទំនាក់ទំនង វិស័យការងារ ដើម្បីធានាការអភិវឌ្ឍន៍ និង ការរក្សាស្ថេរភាពរោងចក្រ សហគ្រាស ក៏ដូចជារក្សាទំនាក់ទំនងរវាងនិយោជិត និង និយោជក។ នៅឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានបង្កើតច្បាប់ការងារជាលើកដំបូង ប៉ុន្តែមកដល់របបប្រល័យពូជសាសន៍ខ្មែរក្រហម (ក្រោយឆ្នាំ១៩៧៥ដល់១៩៧៩) ច្បាប់ទាំងអស់ត្រូវបានលុបបំបាត់ចោលទាំងស្រុង។ ក្រោយមករដ្ឋាភិបាលកម្ពុជា(នៅឆ្នាំ១៩៩២) បានអនុម័តច្បាប់ការងារថ្មីមួយដោយយកគំរូតាមច្បាប់ការងារប្រទេសបារាំង និង ច្បាប់ការងារឆ្នាំ១៩៩២ចាស់។ ច្បាប់ការងារឆ្នាំ១៩៩២នេះក៏បានចែងយ៉ាងច្បាស់អំពីប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាផងដែរ។ បច្ចុប្បន្ននេះវិស័យការងារស្ថិតនៅក្រោមច្បាប់ការងារឆ្នាំ១៩៩៧ ហើយសារណានេះត្រូវផ្អែកទៅលើច្បាប់ការងារឆ្នាំ១៩៩៧នេះគោល។

បើងាកមកមើលពីសង្គមវិញគឺផ្អែកទៅលើការងារជាសំខាន់ ដូច្នេះទីផ្សារការងារត្រូវឆ្លើយតបទៅនឹងបរិបទនយោបាយសេដ្ឋកិច្ច និង សង្គម។ ម៉្យាងទៀត ទីផ្សារការងារពុំទាន់ឆ្លើយតបបានទៅនឹងសង្គមបច្ចុប្បន្ននៅឡើយ ដោយសារយើងនៅខ្វះកម្មករជំនាញ ពីព្រោះកម្មករជំនាញមានត្រឹមតែ ៩.៧%នៃកម្មករសរុប ដូច្នេះយើងនៅត្រូវការកម្មករជំនាញពីក្រៅប្រទេសដូចជា ចិន ថៃ វៀតណាម នៅក្នុងវិស័យសំណង់ ធនាគារ និង វិស័យធានារ៉ាប់រង។ ការទទួលបានប្រាក់ឈ្នួលរបស់កម្មករនិយោជិតមានការប្រែប្រួលទៅតាមនេះដែរ វាអាស្រ័យលើសញ្ញាបត្រ បទពិសោធន៍ការងារក៏ដូចជាជំនាញផងដែរ។ តើប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបានវាគ្រាប់គ្រាន់ដែរឬទេក្នុងការផ្គត់ផ្គង់ជីវភាពរបស់ពួ

កគេ? តើប្រាក់ឈ្នួលការងារមានអ្វីខ្លះ? តើប្រព័ន្ធច្បាប់ការងារពាក់ព័ន្ធនឹងប្រាក់ឈ្នួលកម្មករនិយោជិតមានលើអ្វីខ្លះ? មកដល់ពេលនេះ ចម្លើយទាក់ទងនឹងសំណួរទាំងនេះនៅតែមិនទាន់មានការបកស្រាយបានច្បាស់លាស់នៅឡើយ។ ដើម្បីឆ្លើយតបទៅនឹងចំណោទខាងលើនេះ ទាមទារឲ្យមានការសិក្សាស្រាវជ្រាវមួយដ៏ច្បាស់លាស់និងជាក់លាក់។

សារណានេះ មានគោលបំណងធ្វើការសិក្សាស្វែងយល់អំពីឫសគល់នានា រួមទាំងប្រព័ន្ធច្បាប់ដែលទាក់ទងទៅនឹងការកំណត់ប្រាក់ឈ្នួលការងារ សញ្ញាណនៃប្រាក់ឈ្នួលការងារ ប្រភេទប្រាក់ឈ្នួលការងារ ការវិវត្តនៃប្រាក់ឈ្នួលការងារ និងភាពមិនគ្រប់គ្រាន់នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបាន។

សារណានេះ ធ្វើការស្រាវជ្រាវប្រព័ន្ធច្បាប់ពាក់ព័ន្ធនឹងប្រាក់ឈ្នួលការងារនៃប្រទេសកម្ពុជា ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានារបស់ព្រះរាជាណាចក្រ រួមផ្សំលិខិតបទដ្ឋានថ្នាក់អន្តរជាតិព្រមទាំងគោលការណ៍នានាដែលត្រូវអនុវត្តចំពោះវិស័យនេះ។ ការស្រាវជ្រាវនេះគ្រាន់តែធ្វើការរៀបរៀងបង្ហាញនូវឯកសារដែលមានស្រាប់ទាំងឯកសារជាតិ និងអន្តរជាតិ និងធ្វើការវិភាគ វែកញែករកលទ្ធផលជាលក្ខណៈកណ្ដាលមួយ អ្វីដែលទាក់ទងទៅនឹងប្រាក់ឈ្នួលការងារ និងតម្រូវការរបស់កម្មករនិយោជិតនៃព្រះរាជាណាចក្រកម្ពុជា។

ការស្រាវជ្រាវនេះបានធ្វើឡើងដោយការប្រមូលទិន្នន័យព័ត៌មានតាមវិធីជាច្រើន។ ជាដំបូង គឺតាមរយៈការអាន និង ស្វែងយល់លើកិច្ចការស្រាវជ្រាវកន្លងមកទាក់ទិននឹងប្រាក់ឈ្នួលការងារ បន្ទាប់មកធ្វើការស្វែងយល់បន្ថែមតាមរយៈការអានកម្រងច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងប្រាក់ឈ្នួលការងារនៅប្រទេសកម្ពុជា។ បន្ទាប់មកទៀត ធ្វើការប្រមូលព័ត៌មាន និងទិន្នន័យបំពេញបន្ថែមតាមរយៈរបាយការណ៍ ការបោះពុម្ពផ្សាយរបស់រាជរដ្ឋាភិបាល ក្រសួងឬស្ថាប័ន ឬសារព័ត៌មានក្នុងស្រុក និង ក្រៅស្រុក ដោយភាគច្រើនធ្វើឡើងតាមរយៈបណ្ដាញអ៊ីនធើណេត និង បណ្ណាល័យច្បាប់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ រីឯ ព័ត៌មានទាក់ទងនឹងកម្មករនិយោជិត គឺចុះទៅសួរផ្ទាល់ដល់រោងចក្រជាមួយបងៗកម្មករនិយោជិតតែម្ដង។

សារណានេះ រួមចំណែកក្នុងការផ្ដល់ព័ត៌មានដល់អ្នកសិក្សា និង អ្នកស្រាវជ្រាវនៅព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការស្រាវជ្រាវនេះ បានប្រមូលផ្ដុំនូវពត៌មានជាច្រើននិងការវិភាគបកស្រាយវែកញែកលទ្ធផលថ្មីៗមួយចំនួន ដែលជាប្រយោជន៍សម្រាប់អ្នកសិក្សា សិស្សនិស្សិតដែលធ្វើការស្រាវជ្រាវក្រោយៗទៀត

ដើម្បីធ្វើការស្វែងយល់ និង យកទៅវិភាគពិចារណា។ បន្ថែមពីនេះទៀត សារាណានេះក៏បានផ្តល់នូវពត៌មានទូទៅជាច្រើនសំរាប់សាធារណជនដើម្បីធ្វើការស្វែងយល់បន្ថែមអំពីបច្ចុប្បន្នភាពនៃប្រាក់ឈ្នួលការងារនៅក្នុងប្រទេសកម្ពុជាយើងផងដែរ។ ជាចុងក្រោយនៃសារាណានេះក៏បានវិភាគទៅលើតម្រូវការរបស់កម្មករនិយោជិត ដែលត្រូវការចាំបាច់ខ្លះនៅក្នុងជីវភាពប្រចាំថ្ងៃផងដែរ ព្រមបានផ្តល់នូវអនុសាសន៍មួយចំនួនក្នុងការចូលរួមចំណែក ដើម្បីកែប្រែនូវបញ្ហាដែលពាក់ព័ន្ធនឹងប្រាក់ឈ្នួលនៅក្នុងប្រទេសកម្ពុជា។

ប្រាក់ឈ្នួលនៅទីនេះសំដៅទៅដល់ប្រាក់ដែលកម្មករនិយោជិតទទួលបានជាថ្នូរទៅនឹងការធ្វើការងាររបស់ពួកគេ ហើយសារណានេះសំដៅទៅលើតែប្រាក់ឈ្នួលរបស់កម្មករនិយោជិតមិនមែនទៅលើប្រាក់បៀវត្សន៍របស់មន្ត្រីរាជការដែលធ្វើការក្នុងវិស័យសាធារណៈនោះទេ។

មូលដ្ឋានក្នុងការកំណត់ប្រាក់ឈ្នួលនេះវាអាស្រ័យយ៉ាងខ្លាំងទៅលើកត្តានយោបាយ ដែលមូលដ្ឋាននៃការកំណត់ប្រាក់ឈ្នួលនេះត្រូវបានពឹងផ្អែកទៅលើប្រភេទនៃការងារ និង ការកំណត់ ប្រាក់ឈ្នួល ហើយរាជរដ្ឋាភិបាលបានមើលឃើញ និង ស្វែងយល់ពីតម្រូវការរបស់កម្មករនិយោជិត និង កំពុងតែស្វះស្វែងរកនូវដំណោះស្រាយសម្រាប់កម្មករនិយោជិតក្នុងការប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ។

ដូចនេះ ដើម្បីយល់ច្បាស់ពីរឿងនេះ តើមានមូលដ្ឋានណាខ្លះដើម្បីកំណត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត(ជំពូកទី១) សញ្ញាណនៃប្រាក់ឈ្នួលគឺបង្ហាញពីប្រាក់ឈ្នួលសុទ្ធសាធ និងប្រភេទនៃប្រាក់ឈ្នួលនៃប្រទេសកម្ពុជា(ផ្នែក១) និងការកំណត់ប្រាក់ឈ្នួលសំដៅលើកត្តាសង្គមនិងកត្តា សេដ្ឋកិច្ច(ផ្នែក២) បន្ទាប់មកទៀត តើកត្តានយោបាយចង់សំដៅលើអ្វី(ជំពូកទី២) ដែលបង្ហាញពីការ វិវត្តនៃប្រាក់ឈ្នួល(ផ្នែក១) វិធីនៃការកំណត់ប្រាក់ឈ្នួល(ផ្នែក២) និងលក្ខណៈវិនិច្ឆ័យក្នុងការកំណត់នយោបាយប្រាក់ខែ(ផ្នែក៣)។

# ជំពូកទី១

# មូលដ្ឋាននៃការកំណត់ប្រាក់ខែ

# ជំពូកទី១៖ មូលដ្ឋាននៃការកំណត់ប្រាក់ខែ

## ផ្នែកទី១ សញ្ញាណនៃប្រាក់ឈ្នួល

ប្រាក់ឈ្នួលការងារកើតឡើងតាមរយៈការបង្កើតទំនាក់ទំនងការងាររវាងកម្មករនិយោជិត និង និយោជកដែលភាគីកម្មករនិយោជិតត្រូវតែគោរពនូវកាតព្វកិច្ចរបស់ខ្លួនដោយបំពេញសេវា ឬ បំពេញការងារឲ្យនិយោជកដើម្បីទទួលបានប្រាក់ឈ្នួលការងារ។ ភាគីនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលទៅតាមតម្លៃ ឬ តាមការព្រមព្រៀងក្នុងកិច្ចសន្យាការងារដែលបានចុះជាមួយកម្មករនិយោជិត។ សញ្ញាណនៃប្រាក់ឈ្នួលត្រូវបានកំណត់ផ្សេងៗពីគ្នាទៅតាមបរិបទនៃច្បាប់របស់ប្រទេសនីមួយៗ។ ជាក់ស្តែងច្បាប់ការងាររបស់ប្រទេសកម្ពុជាបានឲ្យនិយមន័យប្រាក់ឈ្នួលថាជាឈ្នួលការងារ ឬ ឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬ ជាការព្រមព្រៀងគ្នាដែលនិយោជកត្រូវបើកឲ្យកម្មករនិយោជិត ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលកើតចេញពីកិច្ចសន្យាការងាររវាង កម្មករនិយោជិតនិងនិយោជក[1]។

សញ្ញាណនៃប្រាក់ឈ្នួល នឹងបង្ហាញអំពីប្រាក់ឈ្នួលសុទ្ធសាធ និង ប្រភេទនៃប្រាក់ឈ្នួល ដែលមាននៅក្នុងប្រទេសកម្ពុជា។

### ១.១. ប្រាក់ឈ្នួលសុទ្ធសាធ

ប្រាក់ឈ្នួលសុទ្ធសាធ គឺជាប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបានជាសាច់ប្រាក់តាមរយៈកិច្ចសន្យាការងារដែលកម្មករនិយោជិតបង្កើតឡើងជាមួយនិយោជក។ និយោជកមានកាតព្វកិច្ច បើកប្រាក់ឈ្នួលសុទ្ធសាធដល់និយោជិតជាទៀងរាល់ខែ (ប្រសិនបើកម្មករនិយោជិតធ្វើការគិតជាខែ) ឬ តាមការកំណត់តាមរយៈកិច្ចសន្យាការងារ ដែលអាចជាការបើកប្រាក់គិតជាសប្តាហ៍ ឬ ដោយការគិតជាបរិមាណតាមផលិតផលដែលកម្មករនិយោជិតសម្រេចបាន។ ប្រាក់ឈ្នួលសុទ្ធសាធត្រូវបែងចែកជាប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលថ្ងៃ និង ប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលយប់។

---

[1] ច្បាប់ការងារ,លេខ ជស/រកម/០៣៩៧/០១,១០ មករា១៩៩៧,មាត្រា១០២

**១.១.១ ប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលថ្ងៃ**

ប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលថ្ងៃ គឺជាប្រភេទប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបាននៅក្នុងអំឡុងពេលធ្វើការវេនថ្ងៃ ដែលការងារនេះកម្មករនិយោជិតត្រូវធ្វើការ ៨ម៉ោងក្នុង១ថ្ងៃ និង មិនលើសពី ៤៨ម៉ោងក្នុង១សប្តាហ៍។

**១.១.២ ប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលយប់**

ចំពោះប្រាក់ឈ្នួលបន្ថែមម៉ោងធ្វើការនៅពេលយប់ កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលស្មើនឹង ២០០% ឬ ពីរដងនៃប្រាក់ឈ្នួលពេលធ្វើការធម្មតា។ ការងារបន្ថែមម៉ោងនៅពេលយប់ គឺជាការធ្វើការនៅចន្លោះពេលពីម៉ោង២២:០០ទៅដល់ម៉ោង៥:០០ភ្លឺ ហើយរយៈពេលធ្វើការ គឺមានចំនួន ១១ម៉ោងយ៉ាងតិចបន្តបន្ទាប់គ្នា [2] ។ ក្រៅពីប្រាក់ម៉ោងបន្ថែមដែលត្រូវបើកឲ្យកម្មករ និយោជិត និយោជកមានកាតព្វកិច្ចផ្តល់ទីកន្លែងសម្រាក និង ទទួលទានដំណេកឲ្យបានសមរម្យដល់កម្មករនិយោជិតដែលចេញធ្វើការម៉ោងបន្ថែមនៅពេលយប់ ឬ ផ្តល់នូវមធ្យោបាយធ្វើដំណើរដល់កម្មករនិយោជិតទៅដល់លំនៅដ្ឋានរៀង១ខ្លួនវិញប្រកបដោយសុវត្ថិភាពនៅពេលដែលបញ្ចប់ម៉ោងការងារនៅពេលយប់[3]។

**១.១.៣ ប្រាក់ឈ្នួលទាបបំផុត**

ជាគោលការណ៍ប្រាក់ឈ្នួលទាបបំផុត ឬ ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា គឺក្រសួងទទួលបន្ទុកវិស័យការងារមានតួនាទីក្នុងការកំណត់បន្ទាប់ពីទទួលយោបល់ពីគណៈកម្មការប្រឹក្សា ការងារ។ ការកំណត់ប្រាក់ឈ្នួលទាបបំផុត ឬ ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាត្រូវផ្អែកទៅលើធាតុផ្សំទាំងឡាយដែលត្រូវយកមកគណនាទៅតាមហេតុផលមួយចំនួនដូចជា៖ (១) សេចក្តីត្រូវការរបស់កម្មករនិយោជិត និង គ្រួសារដោយផ្អែកលើកម្រិតប្រាក់បៀវត្សជាទូទៅក្នុងប្រទេសតម្លៃជីវភាពរស់នៅតាវកាលិកផ្អែកលើសន្តិសុខសង្គម និង កម្រិតជីវភាពដែលប្រៀបធៀបពីក្រុមមួយទៅមួយក្រុម។ (២) កត្តាទាំងឡាយនៃវិស័យសេដ្ឋកិច្ចរួមទាំងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច ផលិតភាព និងផលប្រយោជន៍ដែលត្រូវសម្រេចឲ្យបាននិងរក្សាឲ្យបាននូវកម្រិតដ៏ខ្ពស់នៃមុខរបរ [4] ។ (៣)

---

[2] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១៤៤ថ្មី

[3] ហៃល ចំរើន, នីតិការងារ, (ភ្នំពេញ៖ហ្វូណាន ២០០៥),២០៣

[4] ច្បាប់ការងារ,លេខជស/រកម/០៣៨៧/០១,១០ មករា១៩៩៧.មាត្រា១០៧.កថាខណ្ឌ២.៣

ផ្អែកទៅលើកត្តាសេដ្ឋកិច្ចរបស់ប្រទេស។ មានន័យថា ការកំណត់ប្រាក់ឈ្នួលគឺធ្វើយ៉ាងណាធានាដល់កម្មករនិយោជិតគ្រប់រូប ឲ្យមានជីវភាពរស់នៅសមរម្យទៅតាមសេចក្តីថ្លៃថ្នូររបស់មនុស្សទូទៅ[5]។

នៅក្នុងអំឡុងឆ្នាំ២០១៩ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានសម្រេចផ្តល់ប្រាក់ឈ្នួលទាបបំផុត ឬ ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាដល់កម្មករនិយោជិតចំនួន១៨២ដុល្លារសហរដ្ឋអាមេរិក[6]។ ចំណែកឯការកំណត់ប្រាក់ឈ្នួលទាបបំផុតតាមបរិមាណផលិតផលវិញ កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលទៅតាមបរិមាណផលិតផលដែលសម្រេចបាន មានន័យថារាល់បរិមាណការងារទាំងឡាយណា ដែលកម្មករនិយោជិតធ្វើចេញជាផលិតផលសម្រេចឲ្យ និយោជក និយោជកត្រូវគិតប្រាក់ឈ្នួលតាមបរិមាណដែលសម្រេចនោះ។ ប្រសិនបើផលិតផលដែលកម្មករនិយោជិតធ្វើសម្រេចឲ្យនិយោជកលើសពីប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ឬ ប្រាក់ឈ្នួលទាបបំផុត និយោជកត្រូវតែបើកប្រាក់ឈ្នួលឲ្យកម្មករនិយោជិតតាមផលិតផលជាក់ស្តែងដែលលើស។ ប្រសិនបើផលិតផលដែលកម្មករនិយោជិតសម្រេចឲ្យនិយោជក ឬ និយោជកបានកម្រិតបរិមាណផលិតផលឲ្យកម្មករនិយោជិតសម្រេចតិចជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ឬ ប្រាក់ឈ្នួលទាបបំផុត កម្មករនិយោជិតនៅតែមានសិទ្ធិទទួលបានប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាតាមការកំណត់របស់ក្រសួងដដែល។

### ១.១.៤ សិទ្ធិក្នុងការកំណត់ប្រាក់ឈ្នួលតាមអនុសញ្ញារួម

អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរដែលបានបង្កើតឡើងតាមការព្រមព្រៀងគ្នារវាង៖ (១) និយោជកម្នាក់ និយោជកមួយក្រុម ឬ អង្គការមួយ ឬ អង្គការច្រើនតំណាងឲ្យនិយោជក។ (២) អង្គការសហជីពមួយ ឬ អង្គការសហជីពច្រើនតំណាងឲ្យកម្មករនិយោជិត[7]។ ក្នុងករណីដែលការកំណត់ប្រាក់ឈ្នួលដោយផ្អែកតាមអនុសញ្ញារួមលើសពីប្រាក់ឈ្នួលអប្បបរមាដែល

[5] ច្បាប់ការងារ,លេខជស/រកម/០៣៩៧/០១,១០ មករា១៩៩៧,មាត្រា១០៤

[6] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសម្រាប់ឆ្នាំ២០១៩, លេខ៤៦៥ ក.ប/ប្រ.ក.ខ.ល, ០៥ តុលា ២០១៨

[7] ច្បាប់ការងារ,លេខ ជស/រកម/០៣៩៧/០១,១០ មករា ១៩៥៧.មាត្រា៩៦

ត្រូវធានានោះ គឺជាការកំណត់មួយដ៏ល្អប្រសើរសម្រាប់កម្មករនិយោជិត ពីព្រោះនៅអនុសញ្ញារួមត្រូវបង្កើតឡើងមកដើម្បីផលប្រយោជន៍កម្មករនិយោជិតច្រើនជាងបញ្ញត្តិទាំងឡាយនៃច្បាប់ និង បញ្ញត្តិជាធរមាន។

ប្រសិនបើអនុសញ្ញារួមទាំងឡាយណាដែលបង្កើតឡើងមកមានការកំណត់ប្រាក់ឈ្នួលតិចជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានានោះ នឹងត្រូវចាត់ទុកជាមោឃៈទោះបីជាអនុសញ្ញារួមនោះបង្កើតឡើងដោយមានការយល់ព្រមពីភាគីកម្មករនិយោជិត និងនិយោជកក៏ដោយ។

**១.១.៥ ប្រាក់ឈ្នួលជារូបិយវត្ថុ**

រូបិយវត្ថុ គឺជាប្រភេទនៃប្រាក់សម្រាប់សម្គាល់នូវជាតិនីមួយៗ [8] ។ នៅព្រះរាជាណាចក្រកម្ពុជា រូបិយវត្ថុដែលតំណាងឲ្យប្រទេសគឺប្រាក់រៀល។ រូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជាបានកើតឡើងជាលើកដំបូងនៅសតវត្សទី ៧-៨ មុនគ្រឹស្តសករាជ។ មកដល់ដើមសតវត្សទី១៦ ក្នុងរាជ្យព្រះស្រីជេដ្ឋាធិរាមាធិបតី(ស្តេចកន) ប្រទេសកម្ពុជាបានដាក់រូបិយវត្ថុជាតិខ្មែរដំបូងបំផុតឈ្មោះថាប្រាក់ស្លឹង ដែលនៅសម័យនោះប្រាក់ស្លឹងបានចរាចរនៅក្នុងប្រទេសដើម្បីជួយសម្រួលការដោះដូរទំនិញពាណិជ្ជកម្មជាមួយបរទេស។ រហូតមកដល់ឆ្នាំ១៩៧៩ [9] ប្រទេសកម្ពុជាបានចេញនូវប្រភេទនៃរូបិយវត្ថុមួយទៀត សម្រាប់សម្គាល់ជាតិគឺប្រាក់រៀល ដែលជាប្រភេទប្រាក់រៀលត្រូវបានប្រើប្រាស់រហូតមកដល់បច្ចុប្បន្ន។

ប្រាក់ឈ្នួលជារូបិយវត្ថុត្រូវបានកំណត់សម្រាប់ប្រើប្រាស់ជាទូទៅ ដែលមានបំណងក្នុងការហាមឃាត់ចំពោះការបើកប្រាក់ឈ្នួលជាវត្ថុ និង ហាមឃាត់ចំពោះការបើកប្រាក់ឈ្នួលជារូបិយប័ណ្ណដទៃទៀតផងដែរ។

និយោជកមានកាតព្វកិច្ចត្រូវតែបើកប្រាក់រៀលដល់កម្មករនិយោជិតនៅពេលដែលកម្មករនិយោជិតបានបំពេញការងារឲ្យនិយោជកតាមកិច្ចសន្យាការងារ ឬ តាមការព្រមព្រៀងណាមួយតែប៉ុណ្ណោះ ហើយក្រៅពីប្រាក់រៀល និយោជកពុំត្រូវមានកាតព្វកិច្ចបើកប្រាក់បរទេស ឬ វត្ថុណាមួយដល់កម្មករនិយោជិតឡើយ។

---

[8] ពុទ្ធសាសនបណ្ឌិត,វចនានុក្រមខ្មែរ,(ភ្នំពេញ៖កម្ពុជា, ១៩៦៧),៧៦៨

[9] CEN, "ការកាត់បន្ថយរូបិយវត្ថុនៅកម្ពុជាធ្វើឡើងដោយសន្សឹម"

### ១.១.៦ ប្រាក់ឈ្នួលជារូបិយប័ណ្ណ

ប្រាក់ឈ្នួលជារូបិយប័ណ្ណ គឺជាប្រភេទក្រដាសប្រាក់បរទេសដែលមានដូចជា ប្រាក់ដុល្លារ ប្រាក់យ៉េន ប្រាក់អឺរ៉ូជាដើម[10]។ ដោយសារតែមានការវិវត្តសេដ្ឋកិច្ចពិភពលោក និង ការវិនិយោគបរទេស មកលើប្រទេសកម្ពុជា ព្រមទាំងដើម្បីជួយសម្រួលដល់ការវិនិយោគទាំងនោះក្រសួងទទួលបន្ទុកវិស័យការងារបានចេញសេចក្តីជូនដំណឹងចំនួន៣ និង ប្រកាសចំនួន១ដោយបានលើកយកតម្លៃឯកតាអាមេរិកមកប្រើប្រាស់។ ចំពោះវិស័យវាយនភណ្ឌកាត់ដេរត្រូវប្រើប្រាស់នូវប្រាក់ឈ្នួលជារូបិយប័ណ្ណអន្តរជាតិគឺប្រាក់ដុល្លារសហរដ្ឋអាមេរិក ពីព្រោះប្រាក់ដុល្លារសហរដ្ឋអាមេរិកនៅលើពិភព លោក មានប្រទេសជាច្រើនកំពុងចរាចរការប្រើប្រាស់ និង ធ្វើការវិនិយោគ។ ដូចនេះ ការយករូបិយប័ណ្ណអាមេរិកមកប្រើប្រាស់ជាលិខិតដែលចេញដោយតំណាងអង្គការនីតិប្រតិបត្តិ បានបង្ហាញឲ្យឃើញថា ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណដែលអាចប្រើប្រាស់ជាផ្លូវការនៅក្នុងប្រទេសកម្ពុជាបានផងដែរ [11]។

### ១.២ ប្រភេទនៃប្រាក់ឈ្នួល

ក្រៅពីប្រាក់ឈ្នួលសុទ្ធសាធដែលកម្មករនិយោជិតមានសិទ្ធិទទួលបានពីនិយោជក ក៏នៅមានប្រាក់ឈ្នួលមួយចំនួនទៀត ដែលត្រូវរាប់បញ្ចូលនៅក្នុងប្រភេទនៃប្រាក់ឈ្នួលកម្មករនិយោជិតផងដែរ។ ក្នុងនោះមានដូចជា ប្រាក់បន្ថែមម៉ោង ប្រាក់កំរៃជើងសា ប្រាក់បុព្វលាភ ប្រាក់បំណាច់ប្រាក់ដែលបើកជារង្វាន់ ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ វិភាជន៍សម្រាប់ការឈប់សម្រាក ឬ បំណាច់សម្រាប់ទូទាត់ការឈប់សម្រាក ប្រាក់ដែលនិយោជកត្រូវឲ្យក្នុងការបាត់បង់សមត្ថភាពពលកម្ម និង ប្រាក់ក្នុងពេលឈប់សម្រាកលំហែមាតុភាព[12]។

---

[10] ពុទ្ធសាសនបណ្ឌិត,វចនានុក្រមខ្មែរ,(ភ្នំពេញ,១៩៦៧),៧៦៩

[11] ហៃល ចំរើន,នីតិការងារ,(ភ្នំពេញះហ្វូណន,២០០៥)២១៤

[12] ច្បាប់ការងារ,លេខ ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧.មាត្រា១០៣

### ១.២.១ ប្រាក់ឈ្នួលសម្រាប់ការងារបន្ថែមម៉ោង

ប្រាក់បន្ថែមម៉ោង គឺជាប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបានពីការធ្វើការងារបន្ថែមទៅលើម៉ោងការងារធម្មតា ដែលត្រូវកំណត់នៅក្នុងច្បាប់ស្តីពីការងារ ឬ បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ឬ គ្រឹះស្ថាននានា។ មានន័យថា រាល់ការងារណាដែលកម្មករនិយោជិតធ្វើការលើសពី ៨ម៉ោងក្នុង១ថ្ងៃ ឬ លើសពី៤៨ម៉ោងក្នុង ១សប្តាហ៍នោះគឺជាការងារបន្ថែមម៉ោង[13]។ ការបន្ថែមម៉ោងនេះអាចធ្វើទៅបាន នៅក្នុងអំឡុងពេលថ្ងៃធ្វើការធម្មតាពេលថ្ងៃ ពេលយប់ ឬ ពេលឈប់សម្រាកប្រចាំសប្តាហ៍។ ជាគោលការណ៍ ការបន្ថែមម៉ោងរបស់រោងចក្រ សហគ្រាស ឬ គ្រឹះស្ថាន អាចប្រព្រឹត្តិទៅបានក្នុងករណីដែលមានកិច្ចការប្រញាប់ខុសពីធម្មតា [14] ។ ការបន្ថែមម៉ោងអាចប្រព្រឹត្តិទៅបានចំពោះសហគ្រាស រោងចក្រ ឬ គ្រឹះស្ថានត្រូវតែស្ថិតនៅក្នុងករណីមួយចំនួនដូចជា៖ (១) ការធ្វើបញ្ជីសារពើភណ្ឌ និង តុល្យការ ការកំណត់ពេលវេលាការជំរះបញ្ជី ការបញ្ឈប់គណនេយ្យ។ (២) ដើម្បីឲ្យសហគ្រាសអាចទប់ទល់ទៅនឹងការងារ ដែលមានច្រើនខុសពីធម្មតាដែលបណ្តាលមកពីកាលៈទេសៈប្លែកៗដែលមិនអាចឲ្យនិយោជករង់ចាំវិធានការដទៃទៀត។

ចំពោះនីតិវិធីនៃការស្នើសុំបន្ថែមម៉ោងរបស់រោងចក្រ សហគ្រាស និងគ្រឹះស្ថាននានា ម្ចាស់សហគ្រាស ឬ គ្រឹះស្ថាននោះត្រូវធ្វើលិខិតស្នើសុំចំនួនមួយច្បាប់ និង លិខិតបញ្ជាក់អំពីយោបល់ឯកភាពរបស់ប្រតិភូបុគ្គលពេញសិទ្ធិគ្រប់រូបរបស់សហគ្រាស គ្រឹះស្ថាន ឬ អាចជាមតិឯកភាពពាក់ កណ្តាលនៃចំនួនកម្មករនិយោជិត (ក្នុងករណីដែលសហគ្រាសនោះមិនទាន់មានប្រតិភូបុគ្គលិក) ចំនួនមួយច្បាប់។ ចំពោះគ្រឹះស្ថានទាំងឡាយណាដែលមានទីតាំងនៅរាជធានីភ្នំពេញត្រូវបញ្ជូនសំណុំលិខិតស្នើសុំធ្វើការបន្ថែមម៉ោងទៅនាយកដ្ឋានអធិការការងារនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំណែកឯសហគ្រាស ឬ គ្រឹះស្ថានទាំងឡាយណាដែលមានទីតាំងនៅតាមបណ្តាលវិជ្ជាជីវៈ។ ចំណែកឯសហគ្រាស ឬ គ្រឹះស្ថានទាងឡាយណាដែលមានទីតាំងនៅតាមបណ្តាលខេត្តក្រុងដទៃទៀត ត្រូវបញ្ជូនលិខិតនោះទៅអធិការការងារខេត្តក្រុងនៃមូលដ្ឋាននោះ។

---

[13] ច្បាប់ការងារ,លេខ ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧, មាត្រា១៩១

[14] ច្បាប់ការងារ,លេខ ជស/រកម/០៣៩៧/០១,១០ មករា ១៩៩៧, មាត្រា១៣៩ថ្មី

រយៈពេលបញ្ជូនសំណុំលិខិតទៅនាយកដ្ឋានអធិការការងារប្រចាំខេត្តក្រុងមានរយៈពេល ១៥ថ្ងៃមុនការចាប់ផ្តើមធ្វើការបន្ថែមម៉ោង។

ការធ្វើការបន្ថែមម៉ោងត្រូវគោរពនូវគោលការណ៍ស្ម័គ្រចិត្តពោលគឺ ម្ចាស់ ឬ នាយកសហគ្រាស រោងចក្រ ឬ គ្រឹះស្ថានមិនត្រូវបង្ខិតបង្ខំ ឬដាក់វិន័យផ្សេងៗចំពោះកម្មករនិយោជិតណាដែលមិនព្រមធ្វើការងារបន្ថែមម៉ោងឡើយ[15]។

ប្រាក់ឈ្នួលបន្ថែមម៉ោងត្រូវបានបែងចែកជាបួនប្រភេទផ្សេងទៀតដែលមានដូចជា ប្រាក់ឈ្នួលបន្ថែមម៉ោងពេលថ្ងៃ ប្រាក់ឈ្នួលបន្ថែមម៉ោងពេលយប់ ប្រាក់ឈ្នួលបន្ថែមម៉ោងចុងសប្តាហ៍ និង ប្រាក់ថ្លៃបាយសម្រាប់ការងារបន្ថែមម៉ោង។

**ក. ប្រាក់ឈ្នួលបន្ថែមម៉ោងចំពោះការងារពេលថ្ងៃ**

ប្រាក់បន្ថែមម៉ោងចំពោះការងារពេលថ្ងៃ ត្រូវមានអត្រាតម្លើង៥០% លើប្រាក់ឈ្នួលពេលធ្វើការធម្មតា ឬ ស្មើនឹង ១៥០% ឬស្មើនឹងមួយដងកន្លះនៃប្រាក់ឈ្នួលពេលធ្វើការធម្មតាចំពោះការងារបន្ថែមម៉ោងនៅពេលថ្ងៃធម្មតា (ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍)។

**ខ. ប្រាក់ឈ្នួលបន្ថែមម៉ោងចំពោះការងារពេលយប់**

ចំពោះប្រាក់ឈ្នួលបន្ថែមម៉ោងធ្វើការនៅពេលយប់ កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលស្មើនឹង ២០០% ឬ ពីរដងនៃប្រាក់ឈ្នួលពេលធ្វើការធម្មតា។ ការងារបន្ថែមម៉ោងនៅពេលយប់ គឺជាការធ្វើការនៅចន្លោះពេលពីម៉ោង២២:០០ទៅដល់ម៉ោង៥:០០ភ្លឺ ហើយរយៈពេលធ្វើការ គឺមានចំនួន ១១ម៉ោងយ៉ាងតិចបន្តបន្ទាប់គ្នា [16] ។ ក្រៅពីប្រាក់ម៉ោងបន្ថែមដែលត្រូវបើកឲ្យកម្មករ និយោជិត និយោជកមានកាតព្វកិច្ចផ្តល់ទីកន្លែងសម្រាក និង ទទួលទានដំណេកឲ្យបានសមរម្យដល់កម្មករនិយោជិតដែលចេញធ្វើការម៉ោងបន្ថែមនៅពេលយប់ ឬ ផ្តល់នូវមធ្យោបាយធ្វើដំណើរដល់កម្មករនិយោជិតទៅដល់លំនៅដ្ឋានរៀងៗខ្លួនវិញប្រកបដោយសុវត្ថិភាពនៅពេលដែលបញ្ចប់ម៉ោងការងារនៅពេលយប់[17]។

[15] ប្រកាសស្តីពីការធ្វើការងារបន្ថែមម៉ោងក្រៅពីចិរវេលាធម្មតា,លេខ៨០ សកបយ,០១ មីនា ១៩៩៩

[16] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១៤៨ថ្មី

[17] ហ៊ែល ចំរើន, នីតិការងារ, (ភ្នំពេញះហ្វូណន ២០០៥),២០៣

**គ. ប្រាក់បន្ថែមម៉ោងសម្រាប់ថ្ងៃឈប់សម្រាកចុងសប្តាហ៍**

ប្រសិនបើនិយោជកមានកិច្ចការប្រញាប់ខុសពីធម្មតា និយោជកអាចស្នើឲ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងនៅថ្ងៃឈប់សម្រាកចុងសប្តាហ៍តាមការស្ម័គ្រចិត្តរបស់កម្មករនិយោជិត ដោយកម្មករនិយោជិតនឹងទទួលបានប្រាក់ឈ្នួលដែលមានអត្រាតម្លើង ១០០% នៃប្រាក់ឈ្នួលធម្មតា ឬស្មើនឹង ២០០% ឬពីរដងនៃប្រាក់ឈ្នួលធម្មតា។

**ឃ. ប្រាក់ថ្លៃបាយសម្រាប់ការងារបន្ថែមម៉ោង**

កម្មករនិយោជិតណាដែលបានយល់ព្រមធ្វើបន្ថែមម៉ោងតាមសំណូមពររបស់និយោជកនោះ កម្មករនិយោជិតត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន២០០០រៀលក្នុង១ថ្ងៃសម្រាប់ថ្លៃអាហារ ឬក៏ទទួលបានដោយការផ្តល់ជូនបាយមួយពេលពីនិយោជកដោយឥតគិតថ្លៃ។ ការផ្តល់ជូននេះអាចឲ្យ នៅពាក់កណ្តាលម៉ោង ឬមុនចាប់ផ្តើមធ្វើការងារថែមម៉ោង[18]។

**១.២.២ ប្រាក់ឈ្នួលតាមឋានានុក្រមការងារ**

**ក. កូនជាង**

កូនជាង គឺជាជនដែលបានចុះកិច្ចសន្យាវិជ្ជាជីវៈជាមួយនឹងនិយោជក ឬសិប្បករណាម្នាក់ដែលបានចុះកិច្ចសន្យានឹងគ្នាថា និយោជកត្រូវបង្រៀន ឬប្រើឲ្យគេបង្រៀនវិជ្ជាជីវៈខ្លួន។ កូនជាងត្រូវធ្វើការងារឲ្យនិយោជកតាមលក្ខខណ្ឌ និងក្នុងរយៈពេលនៃកិច្ចសន្យាតែប៉ុណ្ណោះ ដែលចិរវេលានៃកិច្ចសន្យានេះមិនអាចលើសពី ២ឆ្នាំបានឡើយ [19] ។ កូនជាងអាចទទួលបានប្រាក់ឈ្នួលតាមការចុះកិច្ចសន្យាជាមួយនិយោជកដែលជាអ្នកបង្រៀនខ្លួន ពីព្រោះនៅក្នុងកិច្ចសន្យាការងារ កូនជាងអាចចរចារជាមួយនិយោជកក្នុងការកំណត់កំរៃនៃប្រាក់ឈ្នួលបាន[20]។

**ខ. ការងារសាកល្បង**

ការងារសាកល្បង គឺជាការងារមួយដែលតម្រូវឲ្យកម្មករនិយោជិតធ្វើការជូននិយោជកនៅក្នុងអំឡុងពេលណាមួយដែលកម្មករនិយោជិតបានព្រមព្រៀងគ្នាជាមួយនិយោជក។ ជាគោល ការណ៍

[18] សេចក្តីជូនដំណឹងលេខ០៤១/១១ ក.ប/ស/ជ.ណ, ០៧ មីនា ២០១១

[19] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា៨ និងមាត្រា៥១

[20] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា៥៣

ការចុះកិច្ចសន្យាការងារសាកល្បង មិនអាចមានថិរវេលាលើសពីកាលបរិច្ឆេទជាចាំបាច់សម្រាប់ឲ្យនិយោជកវិនិច្ឆ័យវិជ្ជាជីវៈនៃកម្មករនិយោជិត ហើយកម្មករនិយោជិតក៏បានស្គាល់លក្ខខណ្ឌការងារដែលបានផ្តល់ឲ្យផងដែរ។ ថិរវេលាចំពោះការងារសាកល្បងមិនលើសពីថិរវេលាបីខែ ចំពោះនិយោជិតពីរខែសម្រាប់កម្មករឯកទេស និង ១ខែសម្រាប់កម្មករធម្មតា[21]។ ចំណែកឯការកំណត់ប្រាក់ឈ្នួលនៅក្នុងការងារសាកល្បង គឺអាស្រ័យទៅការកំណត់របស់ក្រសួងមានសមត្ថកិច្ច ទទួលបន្ទុកវិស័យការងារ។ នៅក្នុងឆ្នាំ២០១៩[22] ក្រសួងបានចេញសេចក្តីជូនដំណឹងដោយកំណត់ប្រាក់ឈ្នួលកម្មករនិយោជិតក្នុងការងារសាកល្បងចំនួន១៧៧ដុល្លារសហរដ្ឋអាមេរិក គឺ ប្រាក់ឈ្នួលអប្បបរមា។

**គ. កម្មករពេញសិទ្ធិ**

កម្មករពេញសិទ្ធិ គឺជាកម្មករទាំងឡាយណាដែលបញ្ចប់ការងារសាកល្បងតាមការកំណត់របស់ច្បាប់ ឬដល់ពេលកំណត់នៃកិច្ចសន្យាការងារសាកល្បង។ នៅពេលបញ្ចប់ការងារសាកល្បងកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាតាមការកំណត់របស់ ក្រសួង។ ក្នុងឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានកំណត់ប្រាក់ឈ្នួលកម្មករនិយោជិតពេញសិទ្ធិចំនួន ១៨២ ដុល្លារសហរដ្ឋអាមេរិក គឺជាប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នចំនួន១៧៧ ដុល្លារសហរដ្ឋអាមេរិក។

**១.២.៣ ប្រាក់ផ្សេងៗគិតបញ្ចូលក្នុងប្រាក់ឈ្នួល**

ប្រាក់ផ្សេងៗដែលគិតបញ្ចូលក្នុងប្រាក់ឈ្នួលមានដូចជា៖ ប្រាក់បុព្វលាភ ប្រាក់បំណាច់ប្រាក់វិភាជន៍សម្រាប់ការឈប់សម្រាក ប្រាក់កំរៃជើងសា ប្រាក់ធានានុគ្រោះ ប្រាក់តម្លៃអត្ថប្រយោជន៍ជាវត្ថុ ភាគកម្មក្នុងប្រាក់ចំណេញ ប្រាក់រង្វាន់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីច្បាប់តម្រូវ ប្រាក់ក្នុងពេលបាត់បង់សមត្ថភាព និងឈប់សម្រាកលំហែមាតុភាព។

[21] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា៦៨

[22] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសម្រាប់ឆ្នាំ២០១៩, លេខ៤៦៥ ក.ប/ប្រ.ក.ខ.ល, ០៥/០៥/២០១៨

**ក.ប្រាក់បុព្វលាភ**

ប្រាក់បុព្វលាភត្រូវបានរាប់បញ្ចូល គឺជាធាតុផ្សំមួយនៃប្រាក់ឈ្នួលផងដែរ។ ប្រាក់បុព្វលាភគឺជាប្រភេទនៃប្រាក់អ្វីនោះពុំទាន់មានបញ្ញត្តិណាមួយបានចែងច្បាស់លាស់ឡើយទេ គ្រាន់តែនៅ ក្នុងច្បាប់ការងាររបស់ប្រទេសកម្ពុជាបានចាត់ទុកថាប្រាក់បុព្វលាភ គឺជាប្រភេទប្រាក់ដែលត្រូវបាន រាប់បញ្ចូលនៅក្នុងប្រាក់ឈ្នួលការងារ[23]។

**ខ. ប្រាក់បំណាច់**

ប្រាក់បំណាច់ គឺជាប្រាក់ដែលកម្មករនិយោជិតបើកផ្តាច់នៅពេលដែលបញ្ចប់ ឬ រំលាយកិច្ចសន្យាការងារ។ ប្រាក់បំណាច់ចែកជា៖ (១) ប្រាក់បំណាច់បណ្តេញចេញ (២) ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ (៣) ប្រាក់ទូទាត់ប្រាក់សងជម្ងឺចិត្ត (៤) ប្រាក់បំណាច់ចំពោះការមិនជូនដំណឹងក្នុងការបញ្ចប់កិច្ចសន្យាការងារ។

**ខ.១. ប្រាក់បំណាច់បណ្តេញចេញ**

ប្រាក់បំណាច់បណ្តេញចេញ ត្រូវបានអនុវត្តចំពោះកិច្ចសន្យាការងារមានថិរវេលាកំណត់។ មានន័យថា ក្នុងករណីដែលកិច្ចសន្យាការងារមួយត្រូវបានបញ្ចប់ដោយធន្ទៈភាគីនិយោជកតែម្ខាង និយោជកត្រូវតែផ្តល់ឲ្យកម្មករនិយោជិតដែលខ្លួនបានបញ្ឈប់ ឬ រំលាយកិច្ចសន្យាការងារនោះនូវប្រាក់បំណាច់បណ្តេញចេញ ព្រមទាំងធ្វើការជូនដំណឹងមុនពេលនៃការរំលាយកិច្ចសន្យាការងារនោះផងដែរ។ លើកលែងតែក្នុងករណី ដែលកម្មករនិយោជិតនោះមានកំហុសធ្ងន់ធ្ងរ។ ក្រៅពីអត្ថប្រយោជន៍នៃការជូនដំណឹង កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់បំណាច់បណ្តេញចេញ ដែលត្រូវបានកំណត់ដូច តទៅ៖

- ប្រាក់ឈ្នួល និង ប្រាក់បន្ទាប់បន្សំចំនួនប្រាំពីរថ្ងៃចំពោះកម្មករនិយោជិត ដែលធ្វើការជាប់ជាប្រចាំចាប់ពី ៦ខែ ដល់១២ខែ។
- ចំពោះថិរវេលាធ្វើការងារចាប់ពី១២ខែឡើងទៅ ប្រាក់បំណាច់បណ្តេញចេញត្រូវ គណនាស្មើនឹងប្រាក់ឈ្នួល ព្រមទាំងប្រាក់បន្ទាប់បន្សំចំនួន ១៥ថ្ងៃក្នុងមួយឆ្នាំនៃ ការងារ។ លើសពីនេះទៅទៀត ជាទូទៅប្រាក់អតិបរមាបណ្តេញចេញមិនអាចលើសពីប្រាក់ឈ្នួលបូកនឹងប្រាក់បន្ទាប់ បន្សំចំនួន ៦ខែ ឡើយ។ បើក្នុងករណីថិរវេលាលើសពី១ឆ្នាំ

[23] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១០២

ហើយមានប្រភាគថិរវេលាលើសពី៦ខែឡើងទៅ ត្រូវគិតស្មើនឹង១ឆ្នាំពេញ។ ម្យ៉ាងទៀត ប្រាក់បំណាច់នេះក៏ត្រូវបើកឲ្យកម្មករនិយោជិតផងដែរ ក្នុងករណីដែលការបញ្ឈប់កម្មករនិយោជិតដោយមូលហេតុជម្ងឺ។

- ចំពោះករណីប្រធានសក្តិដូចជា គ្រោះមហន្តរាយ គ្រោះទឹកជំនន់ រញ្ជួយផែនដី ឬសង្គ្រាមដែលធ្វើឲ្យអន្តរាយសម្ភារៈការងារ នាំឲ្យមិនមានការងារធ្វើអស់រយៈពេលយូរ ឬមរណភាពរបស់និយោជកដែលឈានដល់ការបិទគ្រឹះស្ថាន ឬ រោងចក្រ កម្មករនិយោ-ជិតមានសិទ្ធិទទួលបានប្រាក់បំណាច់ ស្មើនឹងរយៈពេលនៃការបញ្ចប់កិច្ចសន្យាការងារតាមការជូនដំណឹងមុន។ ប៉ុន្តែក្នុងករណី ដែលកម្មករនិយោជិតឈប់ធ្វើការងារដោយឯកឯង បញ្ហានេះមិនត្រូវឲ្យនិយោជកចំណាយលើប្រាក់បំណាច់អ្វីទាំងអស់។ ប៉ុន្តែបើការបញ្ចប់កិច្ចសន្យាដោយសារតែអំពើអាក្រក់របស់និយោជក នោះកម្មករនិយោជិតនឹងត្រូវទទួលបាននូវប្រាក់បំណាច់បណ្តេញចេញ។

**ខ.២. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ**

ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ គឺជាប្រភេទប្រាក់បំណាច់ដែលមានលក្ខណៈដូចនឹងប្រាក់បំណាច់បណ្តេញចេញផងដែរ ប្រាក់នេះតម្រូវឲ្យនិយោជកបើកឲ្យកម្មករនិយោជិតនៅពេលដែលបញ្ចប់កិច្ចសន្យាការងារ។ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារនេះត្រូវអនុវត្តក្នុងកិច្ចសន្យាការងារដែលមានថិរវេលាកំណត់។ កិច្ចសន្យាការងារដែលមានថិរវេលាកំណត់ត្រូវបានបញ្ចប់នៅពេលដែលការកំណត់មកដល់ ឬ ដោយមានការព្រមព្រៀងគ្នាកំណត់អំពីការបញ្ចប់ ឬ ក្នុងករណីដែលមានកំហុសធ្ងន់ធ្ងរ ឬ ប្រធានសក្តិ[24]។ នៅពេលដែលកិច្ចសន្យាការងារត្រូវបានបញ្ចប់ ទោះបីស្ថិតក្នុងមូលហេតុខាងលើណាមួយក៏ដោយ ក៏កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់បំណាច់ដែលសមាមាត្រទៅនឹងប្រាក់ឈ្នួល សមាមាត្រទៅនឹងថិរវេលាក្នុងកិច្ចសន្យាការងារដែលបានធ្វើ ព្រមទាំងទទួលបានប្រាក់បំណាច់ដែលត្រូវកំណត់នៅក្នុងអនុសញ្ញារួមផងដែរ។ ប៉ុន្តែក្នុងករណីដែលមិនបានកំណត់នៅក្នុងអនុសញ្ញារួមទេ

[24] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា៧៣

ប្រាក់បំណាច់នេះត្រូវបានកំណត់យ៉ាងតិចស្មើនឹងចំនួន ៥% ដែលកម្មករនិយោជិតត្រូវបើកក្នុងរយៈពេលនៃកិច្ចសន្យាការងារ[25]។

### ខ.៣. ប្រាក់ទូទាត់ចំពោះការមិនជូនដំណឹង

ប្រាក់ទូទាត់ចំពោះការមិនជូនដំណឹង អនុវត្តតែចំពោះកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់តែប៉ុណ្ណោះ។ ចំពោះកិច្ចសន្យាការងារដែលមានថិរវេលាកំណត់វិញ ទោះបីជាមានការកំណត់អំពីការបញ្ចប់ការងារក៏ដោយ កម្មករនិយោជិតពុំមានសិទ្ធិទទួលបានប្រាក់បំណាច់ក្នុងការមិនជូនដំណឹងឡើយ ពីព្រោះនៅក្នុងកិច្ចសន្យាការងារមានថិរវេលាកំណត់ បើមិនបានជូនដំណឹងមុនពេលការបញ្ចប់កិច្ចសន្យាការងារនោះទេ កិច្ចសន្យាការងារនឹងត្រូវបន្តជាស្វ័យប្រវត្តិដោយមានថិរវេលាស្មើនឹងកិច្ចសន្យាការងារដែលបានចុះជាលើកដំបូង។ ប៉ុន្តែក្នុងករណីដែលនិយោជកមិនបានជូនដំណឹងពីកាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាមកដល់កម្មករនិយោជិតទេ កម្មករនិយោជិតមានសិទ្ធិទទួលបានត្រឹមតែប្រាក់ជម្ងឺចិត្តនៃការផ្ដាច់កិច្ចសន្យាថ្មីដែលត្រូវបន្តពីកិច្ចសន្យាចាស់តែប៉ុណ្ណោះ។ ការរំលាយកិច្ចសន្យាការងារមានថិរវេលាមិនកំណត់របស់និយោជក ក្រៅពីមូលហេតុកំហុសធ្ងន់របស់កម្មករនិយោជិត ឬប្រធានសក្តិដែលកើតមានទៅលើភាគីនិយោជក ទោះបីកម្មករនិយោជិតមានជម្ងឺរ៉ាំរ៉ៃ វិកលចរិត ឬពិការក៏ដោយ ក៏កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ទូទាត់អំពីការមិនជូនដំណឹងក្នុងការបញ្ចប់កិច្ចសន្យាការងារបានដែរ។

ថិរវេលាដែលត្រូវជូនដំណឹងមុនត្រូវកំណត់ដូចតទៅ[26]៖

- ៧ថ្ងៃ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសតិចជាង ៦ខែ។
- ១៥ថ្ងៃ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសចាប់ពី ៦ខែ ទៅ២ឆ្នាំ។
- ១ខែ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសលើសពី ២ឆ្នាំ រហូតដល់ ៥ឆ្នាំ។
- ២ខែ បើកម្មករនិយោជិតធ្វើការក្នុងសហគ្រាសលើសពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។
- ៣ខែ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសចាប់ពី ១០ឆ្នាំ ឡើងទៅ។

[25] ដាញែល អាដលរ័ និងផ្សេងទៀត, សៀវភៅណែនាំអំពី ច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជា សំរាប់វិស័យកាត់ដេរ,(ភ្នំពេញ៖DESIGN GROUP,2013),១១២

[26] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា៧៥

ដូច្នេះ ក្នុងករណីដែលនិយោជកមិនបានជូនដំណឹងនៅពេលបញ្ចប់ការងាររបស់កម្មករនិយោជិតទេនោះ

កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ទូទាត់ចំពោះការមិនបានជូនដំណឹងដោយគណនាតាមរូបមន្តដូចខាងក្រោម៖

ប្រាក់ទូទាត់ចំពោះការមិនបានជូនដំណឹង = (ប្រាក់ឈ្នួល + អត្ថប្រយោជន៍ផ្សេងៗ) x រយៈពេលជូនដំណឹង។

**១.២.៤ ប្រាក់ជម្ងឺចិត្ត (កិច្ចសន្យាការងារមានថិរវេលាកំណត់)**

កម្មករនិយោជិត មានសិទ្ធិទទួលបានប្រាក់ជម្ងឺចិត្តយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលកម្មករនិយោជិតដែលទទួលបានរហូតដល់ពេលចប់កិច្ចសន្យាការងារ ក្នុងករណីដែលនិយោជកបានបញ្ចប់កិច្ចសន្យាការងារដោយឆន្ទៈរបស់ខ្លួនជាឯកតោភាគីមុនពេលកំណត់[27]។ ប៉ុន្តែលើកលែងតែក្នុងករណីកិច្ចសន្យាការងារដល់ថិរវេលាត្រូវបញ្ចប់ ឬ ដោយមានការព្រមព្រៀងរវាងកម្មករនិយោជិត និង និយោជកជាលាយល័ក្ខណ៍អក្សរនៅចំពោះមុខអធិការការងារ ដោយមានការចុះហត្ថលេខាត្រឹមត្រូវរវាងភាគីទាំងពីរនៃកិច្ចសន្យាថានឹងបញ្ចប់ការងារមុនពេលកំណត់ ឬ កម្មករនិយោជិតមានកំហុសធ្ងន់ ឬ ករណីប្រធានសក្តិតែប៉ុណ្ណោះទើបកម្មករនិយោជិតមិនអាចទទួលប្រាក់ជម្ងឺចិត្តបាន។

**១.២.៥ ប្រាក់ជម្ងឺចិត្ត (កិច្ចសន្យាការងារមានថិរវេលាមិនកំណត់)**

ចំពោះប្រាក់ជម្ងឺចិត្តនៃកិច្ចសន្យាការងារមានថិរវេលាមិនកំណត់វិញ កម្មករនិយោជិតមានសិទ្ធិទទួលបាននៅពេលដែលនិយោជកបានរំលាយកិច្ចសន្យាការងារជាឯកតោភាគី ដោយគ្មានមូលហេតុត្រឹមត្រូវទាក់ទងទៅនឹងសម្បទា ចរិយារបស់កម្មករនិយោជិតយោងទៅតាមស្ថានភាពចាំបាច់នៃដំណើរការរបស់សហគ្រាស ឬ គ្រឹះស្ថាន។

ប៉ុន្តែក្នុងករណី ដែលកម្មករនិយោជិតបានរំលាយកិច្ចសន្យាការងារដោយឯកតោភាគីវិញ កម្មករនិយោជិតនោះនឹងពុំអាចទទួលបាននូវប្រាក់សោហ៊ុយជម្ងឺចិត្តឡើយ។ លើកលែងតែការរំលាយកិច្ច សន្យារបស់កម្មករនិយោជិតនោះ

[27] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា៩៤

កើតឡើងដោយអំពើអាក្រក់របស់និយោជកដែលជាហេតុនាំឲ្យកម្មករនិយោជិតរំលាយកិច្ចសន្យា ហើយកម្មករនិយោជិតមានសិទ្ធិទទួលប្រាក់ជម្ងឺចិត្តស្មើនឹងប្រាក់បំណាច់បណ្តេញចេញ។ ប្រាក់ជម្ងឺចិត្តនេះត្រូវផ្អែកទៅតាមទំលាប់ក្នុងស្រុក តាមប្រទេស ឬ ទំហំនៃសេវាដែលបានចុះកិច្ចសន្យាតាមអតីតភាព អាយុកម្មករនិយោជិតតាមប្រាក់ដែលបានកាត់ទុក ឬ សម្រាប់សោធននិវត្តន៍ និង ទំហំនៃការខូចខាតនោះ[28]។

### ១.២.៦ ប្រាក់វិភាជន៍សម្រាប់ឈប់សម្រាក

ប្រាក់វិភាជន៍សម្រាប់ការឈប់សម្រាក គឺជាប្រាក់ដែលត្រូវទូទាត់បើកឲ្យកម្មករនិយោជិតនៅថ្ងៃឈប់សម្រាកដែលច្បាប់ ឬ ប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារបានកំណត់ថា កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលនៅថ្ងៃឈប់សម្រាក។

ប្រាក់វិភាជន៍សម្រាប់ការឈប់សម្រាកមានជាច្រើនប្រភេទដូចជា វិភាជន៍សម្រាប់ការឈប់សម្រាកថ្ងៃបុណ្យ ការឈប់ប្រចាំឆ្នាំមានប្រាក់ឈ្នួល ការឈប់សម្រាកពីរថ្ងៃក្នុង១សប្តាហ៍ដែលមានប្រាក់ឈ្នួល និង ការឈប់សម្រាកពិសេសមានប្រាក់ឈ្នួល។

#### ក. វិភាជន៍សម្រាប់ការឈប់សម្រាកថ្ងៃបុណ្យ

ជាគោលការណ៍ក្រសួងទទួលបន្ទុកវិស័យការងារ ជាអ្នកមានសមត្ថកិច្ចក្នុងការចេញសេចក្តីប្រកាសកំណត់ថ្ងៃបុណ្យនៃការឈប់សម្រាក ដែលផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត។

ប្រកាសការឈប់សម្រាកថ្ងៃបុណ្យនេះត្រូវប្រកាសឡើងមុនដើមឆ្នាំថ្មីក្នុងឆ្នាំនីមួយៗ។ នៅដើមឆ្នាំ២០១៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីប្រកាសមួយក្នុងការកំណត់ការឈប់សម្រាកថ្ងៃបុណ្យសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលផងដែរ[29]។ ក្នុងករណីការឈប់សម្រាកថ្ងៃបុណ្យប៉ះថ្ងៃអាទិត្យនោះ កម្មករនិយោជិតនឹងត្រូវបានលើកឲ្យឈប់សម្រាកមួយថ្ងៃទៀត គឺថ្ងៃបន្ទាប់ពីថ្ងៃអាទិត្យ។ ការឈប់សម្រាកថ្ងៃបុណ្យនេះមិនមែនជាមូលហេតុនាំឲ្យកាត់បន្ថយប្រាក់ឈ្នួលកម្មករនិយោជិតប្រចាំខែ ឬ ប្រចាំសប្តាហ៍ឡើយ។ ចំពោះកម្មករនិយោជិតទាំងឡាយណាដែលធ្វើការទទួលបានប្រាក់ឈ្នួលតាមម៉ោងប្រចាំថ្ងៃ ឬ

---

[28] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា៨៥

[29] ប្រកាសស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល, លេខ២៤៨ កប/ប្រក, ២២ តុលា ២០១៤

តាមបរិមាណផលិតផលដែលខ្លួនអាចធ្វើការបាននោះ
កម្មករនិយោជិតនោះមានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួលដែលខ្លួនពុំអាចទទួលបាន
ដែលបណ្តាលមកពីរការឈប់សម្រាកថ្ងៃបុណ្យ។
និយោជកជាអ្នកទទួលបន្ទុកទាំងស្រុងចំពោះប្រាក់ឈ្នួលនេះ។

### ខ. ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល

កម្មករនិយោជិតមានសិទ្ធិទទួលបានការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល
ដែលនិយោជកជាអ្នកផ្តល់ឲ្យចំពោះកម្មករនិយោជិតដែលបានធ្វើការពេញម៉ោង។
សិទ្ធិឈប់សម្រាករួមមាន មួយថ្ងៃកន្លះក្នុងមួយខែ ឬ ដប់ប្រាំបីថ្ងៃក្នុងមួយឆ្នាំ
សម្រាប់រយៈពេលដែលកម្មករនិយោជិតបានធ្វើការជាប់គ្នា។
កម្មករនិយោជិតណាដែលធ្វើការងារមិនទៀតទាត់ក្នុងមួយឆ្នាំ ប៉ុន្តែបានធ្វើការក្នុងមួយខែជាមធ្យម
២១ថ្ងៃ នោះត្រូវចាត់ទុកថាបានធ្វើការងារជាប់លាប់[30]។

ចំពោះការពន្យាពេលឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិតមិនអាចលើសពី៣ឆ្នាំ
បន្តបន្ទាប់គ្នាបានឡើយ
ហើយអាចអនុវត្តបានចំពោះតែភាគនៃការឈប់សម្រាកណាដែលបានហួសពី១២ថ្ងៃដែលជាថ្ងៃធ្វើការ
ក្នុងមួយឆ្នាំ។
ម្យ៉ាងវិញទៀតអនុសញ្ញារួមទាំងឡាយណាដែលគ្រោងឲ្យប្រាក់បំណាច់ទូទាត់សម្រាប់ជួសការឈប់ស
ម្រាក ព្រមទាំងការព្រមព្រៀងដែលស្តីពីការបោះបង់ ឬ
មិនព្រមប្រើប្រាស់សិទ្ធិឈប់សម្រាកប្រចាំឆ្នាំត្រូវចាត់ទុកជាមោឃៈ។
ក្នុងករណីដែលកម្មករនិយោជិតស្ម័គ្រចិត្តលើការឈប់សម្រាកខ្លះ ឬ
ទាំងមូលទៅប្រើនៅពេលចប់កិច្ចសន្យា មិនចាត់ទុកជាការលះបង់ទេ។
កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលពីនិយោជក
នៅមុនថ្ងៃឈប់សម្រាកនូវប្រាក់វិភាជន៍យ៉ាងហោចណាស់ស្មើនឹងចំនួនមធ្យមនៃប្រាក់ឈ្នួលបុព្វលាភ
ប្រាក់វិភាជន៍ ប្រាក់អត្ថប្រយោជន៍ ប្រាក់បំណាច់ ដោយមិនគិតពីប្រាក់បំណាច់សោហ៊ុយ
ដែលកម្មករនិយោជិតបើករួច ហើយឲ្យក្នុងរយៈពេល ១២ខែមុនថ្ងៃឈប់សម្រាកឡើយ។
ក្នុងករណីណាក៏ដោយ

---

[30] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, ផ្នែកទី៦
ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល

ប្រាក់វិភាជន៍មិនត្រូវឲ្យតិចជាងប្រាក់វិភាជន៍ដែលកម្មករនិយោជិតត្រូវបើកនោះទេ កាលបើកម្មករនិយោជិតបានធ្វើការដោយទៀតទាត់។

ចំពោះប្រាក់ឈ្នួលសម្រាប់ការឈប់សម្រាកប្រចាំឆ្នាំ ដែលនិយោជកត្រូវបើកឲ្យកម្មករនិយោជិតនោះត្រូវផ្អែកទៅលើះ

- ប្រាក់កម្មករនិយោជិតទទួលបានជាក់ស្តែងជាមធ្យមក្នុងអំឡុងពេលធ្វើការមួយឆ្នាំមុនពេលឈប់សម្រាកប្រចាំឆ្នាំ។
- ប្រាក់ប្រចាំថ្ងៃដែលកម្មករនិយោជិតអាចទទួលបានប្រសិនបើកម្មករនិយោជិតទៅធ្វើការ។

ចំពោះប្រាក់ទាំងពីរនេះនិយោជកត្រូវផ្តល់ឲ្យកម្មករនិយោជិត ចំពោះប្រាក់ឈ្នួលណា ដែលមានទំហំច្រើនជាង។ នៅពេលដែលកម្មករនិយោជិតបញ្ចប់កិច្ចសន្យាការងារ និយោជកត្រូវតែផ្តល់ប្រាក់ឈ្នួលឲ្យកម្មករនិយោជិតនូវប្រាក់ឈ្នួលពេញថ្លៃសម្រាប់ថ្លៃឈប់សម្រាកដែលនៅសេសសល់។

ចំពោះអនុសញ្ញារួម ឬ កិច្ចសន្យាការងារទាំងឡាយណាដែលបានផ្តល់អត្ថប្រយោជន៍ដល់កម្មករនិយោជិតលើសពីនេះ កម្មករនិយោជិតមានសិទ្ធិទទួលបានអត្ថប្រយោជន៍ឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលស្របតាមអនុសញ្ញារួម ឬ កិច្ចសន្យានោះ។ លើសពីនេះទៅទៀត ក្នុងករណីដែលការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលមានថិរវេលាច្រើនជាងដប់ប្រាំបីថ្ងៃ និយោជកត្រូវមានសិទ្ធិ ទុកថ្ងៃឈប់សម្រាកដែលនៅសល់ទាំងប៉ុន្មានឲ្យឈប់ក្នុងពេលណាមួយផ្សេងទៀតក្នុងឆ្នាំនោះ លើកលែងតែការឈប់សម្រាកការងារក្មេង និង កូនជាងដែលមានអាយុតិចជាង ១៨ឆ្នាំ[31]។

### គ. ការឈប់សម្រាកពីរថ្ងៃក្នុង ១សប្តាហ៍ដែលមានប្រាក់ឈ្នួល

ការឈប់សម្រាកពីរថ្ងៃក្នុង១សប្តាហ៍ដែលមានប្រាក់ឈ្នួល គឺទាក់ទងទៅកិច្ចសន្យាការងារដែលមានថិរវេលាកំណត់ និង កិច្ចសន្យាដែលមានថិរវេលាមិនកំណត់។ ដែលនៅក្នុងកិច្ចសន្យាការងារទាំងពីរនេះបានជាប់ទាក់ទងទៅនឹងអត្ថប្រយោជន៍របស់កម្មករនិយោជិតជាច្រើន ជាពិសេសទាក់ទងទៅនឹងការឲ្យដំណឹងមុនដល់កម្មករនិយោជិតដែលមានសិទ្ធិឈប់ធ្វើការពីរថ្ងៃ

[31] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១៧០

ក្នុង១សប្តាហ៍ដោយមានប្រាក់ឈ្នួល មានន័យថានិយោជកត្រូវជូនដំណឹងដល់កម្មករនិយោជិតមុនពេលបញ្ចប់ការងារ ហើយបានផ្តល់សិទ្ធិឲ្យកម្មករនិយោជិតសម្រាកពីរថ្ងៃ ក្នុង១សប្តាហ៍ដែលមានប្រាក់ឈ្នួលដើម្បីឲ្យកម្មករ និយោជិតរកការងារថ្មី ចំពោះប្រាក់ឈ្នួលក្នុងការឈប់សម្រាកនេះ កម្មករនិយោជិតទទួលបានស្មើនឹងអត្រាការប្រាក់ឈ្នួលធម្មតាប្រចាំថ្ងៃ។

**ឃ. ការឈប់សម្រាកពិសេសដែលមានប្រាក់ឈ្នួល**

ការឈប់សម្រាកពិសេសដែលមានប្រាក់ឈ្នួល គឺជាការឈប់សម្រាកមួយដែលនិយោជកផ្តល់សិទ្ធិអនុញ្ញាតដល់កម្មករនិយោជិតរបស់ខ្លួនផ្ទាល់ឲ្យឈប់សម្រាកមិនលើសពី ៧ថ្ងៃ ក្នុង១ឆ្នាំ នៅក្នុងករណីដែលកម្មករនិយោជិតមានធុរៈផ្ទាល់ខ្លួនដែលមានដូចជា ការរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន ប្តី ប្រពន្ធ កូន ឪពុកម្តាយមានជម្ងឺ ឬ ទទួលមរណភាព[32] ។ ក្នុងករណីការអនុវត្តការឈប់ប្រចាំឆ្នាំមិនអស់ទេ និយោជកមានសិទ្ធិកាត់កងក្នុងការឈប់សម្រាកពិសេសនេះរបស់កម្មករនិយោជិតបាន។ តែបើកម្មករនិយោជិតអនុវត្តការឈប់សម្រាកប្រចាំឆ្នាំអស់ហើយ នោះនិយោជកមិនមានសិទ្ធិក្នុងការកាត់កងការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិតនៅពេលធ្វើការ ដែលទទួលបានការឈប់សម្រាកប្រចាំឆ្នាំតទៅមុខទៀតបានទេ។ ប៉ុន្តែនិយោជកមានសិទ្ធិឲ្យកម្មករនិយោជិតធ្វើការសងវិញ។ ការធ្វើការសងនេះអនុវត្តបានត្រឹមតែក្នុងរយៈពេល ៩០ថ្ងៃក្រោយថ្ងៃឈប់សម្រាកតែប៉ុណ្ណោះ។ ការធ្វើការសងនេះត្រូវ អនុវត្តក្នុងថ្ងៃធ្វើការធម្មតា និង មានលក្ខខណ្ឌដែលមានថិរវេលាសរុបមិនលើសពី១០ម៉ោងក្នុង១ថ្ងៃ ឬលើសពី៥៤ម៉ោងក្នុង១សប្តាហ៍ឡើយ។ ការធ្វើការសងនេះត្រូវផ្តល់ប្រាក់ឈ្នួលតាមអត្រាម៉ោងធ្វើការធម្មតា។

**១.២.៧ ប្រាក់កំរៃជើងសា**

ប្រាក់កំរៃជើងសា គឺជាប្រាក់ដែលកម្មករនិយោជិតទទួលបានក្រៅពីប្រាក់ឈ្នួល និងប្រាក់ឈ្នួលបន្ទាប់បន្សំ ដែលប្រាក់នេះកម្មករនិយោជិតទទួលបានតាមភាគរយនៃលទ្ធផលការងារដែលបានធ្វើស្តែងចេញមក។ ប្រាក់កំរៃជើងសានេះ

[32] ប្រកាសស្តីពីការឈប់សម្រាកពិសេស, លេខ២៦៧ សកបយ, ១៤ តុលា ២០០១

គឺផ្អែកទៅលើសកម្មភាពដែលកម្មករនិយោជិតបានបំពេញការងារដោយទទួលបានលទ្ធផលតិច ឬច្រើនរបស់កម្មករនិយោជិត ហើយព្រមទាំងផ្អែកទៅលើកិច្ចសន្យាការងារផងដែរ។ លើសពីនេះទៅទៀត និយោជកត្រូវរាប់បញ្ចូលប្រាក់កំរៃជើងសានេះ ប្រសិនបើមានក្នុងការគិតប្រាក់ឈ្នួលនៅពេលឈប់សម្រាកមានប្រាក់ឈ្នួល និងនៅពេលដែលគិតប្រាក់បំណាច់បណ្តេញចេញក្នុងករណីដែលដេញចេញ ហើយនៅពេលគិតសោហ៊ុយជម្ងឺចិត្តក្នុងករណីដែលផ្តាច់កិច្ចសន្យាការងារដោយមិនបានប្រាប់មុន ឬក្នុងករណីផ្តាច់កិច្ចសន្យាការងារដោយរំលោភច្បាប់។ វិធីគិតប្រាក់ផ្សេងៗខាងលើនេះត្រូវគិតតាមប្រាក់កំរៃជើងសា ឬ រង្វាន់ជាមធ្យមប្រចាំខែដែលធ្លាប់បានបើកពីមុនមកក្នុងរយៈពេលធ្វើការមិនហួសពី១២ខែ គិតមកដល់ថ្ងៃចេញពីតំណែងចំពោះការឈប់សម្រាក ឬ ឈប់ធ្វើការ [33] ។ ម្យ៉ាងវិញទៀត ប្រាក់កម្រៃជើងសានេះត្រូវបើកយ៉ាងហោចណាស់៣ខែម្តង ដែលខុសពីប្រាក់ឈ្នួលសុទ្ធសាធ ឬប្រាក់ឈ្នួលធម្មតាដែលត្រូវបើក១ខែម្តង។

**១.២.៨ ប្រាក់ធានានុគ្រោះ**

ប្រាក់ធានានុគ្រោះ គឺជាប្រាក់កម្រៃដែលអតិថិជនបានផ្តល់ឲ្យបុគ្គលដែលធ្វើការក្នុងប្រភេទសហគ្រាសដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ហាងកាហ្វេ ឬ ផ្ទះកាហ្វេ ហាងលក់ភេសជ្ជៈ ឬ ផ្ទះ ភេសជ្ជៈ ហាងកាត់សក់ និងកន្លែងមួយចំនួនទៀត ដែលអតិថិជនបានចំណាយលើសពីសេវារបស់និយោជក ដោយអតិថិជនចង់ផ្តល់ប្រាក់ធានានុគ្រោះនេះដល់កម្មករនិយោជិត។ ប្រាក់ធានានុគ្រោះត្រូវបានហៅថា លុយធីប ឬ លុយថ្លៃទឹកតែ ដែលមានចែងនៅក្នុងកិច្ចសន្យាការងារ ។ ប្រាក់ធានានុគ្រោះនេះ កម្មករនិយោជិតទទួលបានពីអតិថិជនដោយផ្ទាល់ដៃដោយសុទ្ធចិត្តផ្ទាល់។ ប្រាក់ធានានុគ្រោះនេះ នៅពេលដែលនិយោជកទទួលបានពីកម្មករនិយោជិតដែលបានមកពីអតិថិជន និយោជក ត្រូវបើកឲ្យកម្មករនិយោជិតដែលទាក់ទងនឹងអតិថិជនវិញទាំងអស់។ លើសពីនេះទៀតនិយោជកក៏ត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីការទទួល និងការប្រគល់ឲ្យកម្មករនិយោជិតវិញនោះ។

[33] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១១០

### ១.២.៩ ប្រាក់ដែលមានតម្លៃអត្ថប្រយោជន៍ជាវត្ថុ

ប្រាក់ដែលមានតម្លៃអត្ថប្រយោជន៍ជាវត្ថុ គឺជាប្រភេទប្រាក់ដែលត្រូវបានរាប់បញ្ចូលនូវវត្ថុមួយចំនួនដែលកម្មករនិយោជិតទទួលបានជាភាគឈ្នួល ដែលសម្រាប់ប្រើប្រាស់ជាសេចក្តីត្រូវការរបស់កម្មករនិយោជិត និង ជាប្រយោជន៍ដល់ក្រុមហ៊ុន ឬ សហគ្រាស ឬ ដល់និយោជកផងដែរ។ អត្ថប្រយោជន៍ដែលជាវត្ថុនេះ និយោជកផ្តល់ឲ្យកម្មករនិយោជិតជាវត្ថុ ក្នុងករណីដែលកម្មករនិយោជិតបានបំពេញតាមលក្ខខណ្ឌដែលមានចែង។ ជាក់ស្តែង មានដូចជាកម្មករនិយោជិតទទួលបានសំលៀកបំពាក់ពលកម្ម ២កំផ្លេក្នុង១នាក់ ក្នុងរយៈពេលមួយឆ្នាំ ដោយឥតគិតថ្លៃចំពោះកម្មករនិយោជិតណាដែលធ្វើការចាប់ពី៦ខែ ឡើងទៅដោយគិតទាំងរយៈពេលសាកល្បងផងដែរ។

### ១.២.១០ ភាគកម្មក្នុងប្រាក់ចំណេញ

ភាគកម្មក្នុងប្រាក់ចំណេញ គឺជាប្រភេទនៃប្រាក់ចំណេញរបស់សហគ្រាស ឬ គ្រឹះស្ថានដែលច្បាប់តម្រូវឲ្យនិយោជកផ្តល់ឲ្យកម្មករនិយោជិតជាប្រាក់បន្ថែមលើប្រាក់ឈ្នួលគោល។ លើសពីនេះទៀត ការបើកប្រាក់ភាគកម្មក្នុងប្រាក់ចំណេញនេះ និយោជកត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។ ការបើកភាគកម្មក្នុងប្រាក់ចំណេញនេះអាស្រ័យទៅលើសហគ្រាស ឬ គ្រឹះស្ថាននីមួយៗ ហើយក៏ជាព័ត៌មានសម្ងាត់របស់និយោជកមិនអាចបង្ហាញបានផងដែរ ។

### ១.២.១១ ប្រាក់រង្វាន់

ប្រាក់រង្វាន់
គឺជាប្រភេទប្រាក់កម្មករនិយោជិតទទួលបានពីនិយោជកដែលទាក់ទងទៅនឹងសកម្មភាពមួយចំនួនរបស់កម្មករនិយោជិត។ ប្រាក់រង្វាន់នេះក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានកំណត់ជាពីរប្រភេទគឺ ប្រាក់រង្វាន់សម្រាប់ការងារទៀងទាត់ និងប្រាក់រង្វាន់អតីតភាព។

#### ក.ប្រាក់រង្វាន់សម្រាប់ការងារទៀងទាត់

ប្រាក់រង្វាន់ចំពោះការងារទៀងតាត់ កម្មករនិយោជិតអាចទទួលបានយ៉ាងតិចចំនួន៥ដុល្លារសហរដ្ឋអាមេរិចក្នុង១ខែ។
ប្រាក់រង្វាន់នេះកម្មករនិយោជិតអាចទទួលបានលុះត្រាតែកម្មករនិយោជិតបានបំពេញការងារទៀងទាត់ក្នុងចំនួនថ្ងៃដែលត្រូវធ្វើការក្នុង១ខែ។ ផ្ទុយទៅវិញក្នុងករណីដែលកម្មករនិយោជិតមិនបានបំពេញការងារឲ្យគ្រប់ចំនួនថ្ងៃធ្វើការទេ
ប្ញូករួមទាំងការឈប់សម្រាកដែលមានជម្ងឺផងដែរនោះ កម្មករនិយោជិតមិនមានសិទ្ធិទទួលបានប្រាក់រង្វាន់នេះឡើយ។

### ខ. ប្រាក់រង្វាន់អតីតភាព

ប្រាក់រង្វាន់អតីតភាពត្រូវបានអនុវត្តចំពោះកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងស្បែកជើង ដោយការតម្លើងប្រាក់ឈ្នួលស្មើនឹង ៥% នៃប្រាក់ឈ្នួលសុទ្ធសាធចំពោះកម្មករនិយោជិតណាដែលមានអតីតភាពការងារ២ឆ្នាំ ៦% ចំពោះកម្មករនិយោជិតដែលអតីតភាពការងារ៤ឆ្នាំ និង ៧% ចំពោះកម្មករនិយោជិតដែលមានអតីតភាពការងារចាប់ពី៦ឆ្នាំឡើងទៅ។ ដោយសារតែការកំណត់អតីតភាពនេះគិតជាភាគរយ ទើបក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹងមួយដោយគិតប្រាក់អតីតភាពជាប្រាក់វិញ ដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការកំណត់ប្រាក់រង្វាន់អតីតភាពនេះ។ ការកំនត់មានដូចតទៅ៖

- ចំពោះកម្មករនិយោជិតដែលបានធ្វើការបាន១ឆ្នាំ ពុំមានសិទ្ធិទទួលបានប្រាក់រង្វាន់ឡើយ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី២ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន២ដុល្លារក្នុង១ខែ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី៣ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន៣ដុល្លារក្នុង១ខែ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី៤ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន៤ដុល្លារក្នុង១ខែ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី៥ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន៥ដុល្លារក្នុង១ខែ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី៦ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន៦ដុល្លារក្នុង១ខែ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី៧ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន៧ដុល្លារក្នុង១ខែ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី៨ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន៨ដុល្លារក្នុង១ខែ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី៩ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន៩ដុល្លារក្នុង១ខែ។
- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី១០ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន១០ដុល្លារក្នុង១ខែ។

- ចំពោះកម្មករនិយោជិតដែលបានធ្វើការចាប់ពី១១ឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន១១ដុល្លារក្នុង១ខែ។

### ១.២.១២ ប្រាក់វិភាជន៍គ្រួសារដែលលើសពីច្បាប់តម្រូវ

ប្រាក់វិភាជន៍ គឺប្រភេទនៃប្រាក់កម្រៃមួយប្រភេទដែលនិយោជក ឬ ម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានផ្តល់ឲ្យកម្មករនិយោជិតបន្ថែមលើប្រាក់ឈ្នួលគោល។ ប្រាក់វិភាជន៍នេះមានបែងចែកជាពីរប្រភេទ គឺប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ និង ប្រាក់វិភាជន៍ឈប់សម្រាក ឬ ប្រាក់បំណាច់សម្រាប់ទូទាត់ការឈប់សម្រាក។

ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវច្បាប់ សំដៅដល់ទឹកប្រាក់ ឬ កម្រៃ ឬ ភាគឈ្នួលដែលនិយោជក ឬ ម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានផ្តល់ ឬឧបសគ្គជារៀងរាល់ខែឲ្យក្រុមគ្រួសាររបស់កម្មករនិយោជិត ឬ បុគ្គលដែលបានបម្រើការងារ ប៉ុន្តែជាក់ស្តែងយើងពុំមានបទប្បញ្ញត្តិណាមួយបានកំណត់ច្បាស់លាស់នោះទេ។ ជាទូទៅ ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសជាអ្នកកំណត់នៅក្នុងអនុសញ្ញារួម។ ឧទាហរណ៍ **ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA BANK Plc)** បានផ្តល់ប្រាក់ឧបត្ថម្ភអោយកូនម្នាក់ៗ ១៥(ដប់ប្រាំ) ដុល្លារអាមេរិកក្នុងមួយខែចំពោះបុគ្គលិកពេញសិទ្ធិ។

## ផ្នែកទី២ ប្រព័ន្ធកំណត់ប្រាក់ខែ

ប្រព័ន្ធនៃការកំណត់ប្រាក់ខែ គឺជាកាតព្វកិច្ចរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ហើយការកំណត់ប្រាក់ខែនេះ គឺត្រូវពឹងផ្អែកលើកត្តាធំៗចំនួនពីរ គឺ កត្តាសង្គម (ស្ថានភាពគ្រួសារ ជីវភាពរស់នៅរបស់ប្រជាជន និង ការចំណាយប្រចាំថ្ងៃក្នុងជីវភាពរស់នៅ) និង កត្តាសេដ្ឋកិច្ច (ទីផ្សារ ការងារ ការប្រកួតប្រជែងក្នុងវិស័យការងារទាំងជាតិ និង អន្តរជាតិ ក៏ដូចជាការវិនិយោគទុនជាដើម)។

### ២.១. កត្តាសង្គម

ការកំណត់ប្រាក់ឈ្នួលដោយផ្អែកលើកត្តាសង្គម គឺជាការកំណត់ប្រាក់ឈ្នួលដែលយ៉ាងតិចណាស់ក៏ត្រូវឲ្យស្មើនឹងប្រាក់ឈ្នួលអប្បបរមា ពោលគឺរ៉ាប់រងកម្មករនិយោជិតគ្រប់រូបឲ្យមានកម្ពស់ជីវភាពសមរម្យទៅតាមសេចក្តីថ្លៃថ្នូររបស់មនុស្ស [34] ។ មានន័យថា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ គឺត្រូវវិភាគទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសព្វថ្ងៃ

[34] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១០៤

ថាតើពួកគាត់មាន ចំនាយទៅលើតម្រូវការអ្វីខ្លះ ទាំងការហូបចុក ការប្រើប្រាស់សម្លៀកបំពាក់ ការចំណាយលើការ សិក្សារៀនសូត្រ ការចំនាយលើថ្នាំព្យាបាលពេលឈឺថ្កាត់ ការចំណាយលើការផ្គត់ផ្គង់ទឹកភ្លើង ការ ចំនាយលើថ្លៃឈ្នួលផ្ទះ ព្រមទាំងការចំនាយលើថ្លៃធ្វើដំណើរ និងការចំនាយផ្សេងៗជាច្រើនទៀត។ ការចំនាយទាំងអស់នេះជាអ្វីដែលក្រសួងត្រូវតែធ្វើការយកចិត្តទុកដាក់គិតគូរកំណត់នូវប្រាក់ឈ្នួលអប្បបរមាយ៉ាងណាឲ្យសមាមាត្រទៅនឹងការចំនាយប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដើម្បីឲ្យពួកគេរស់នៅក្នុងជីវភាពមួយដែលសមរម្យ និង ពុំមានការខ្វះខាតធ្ងន់ធ្ងរក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ។

### ២.២. កត្តាសេដ្ឋកិច្ច

ការកំណត់ប្រាក់ឈ្នួលដោយផ្អែកលើកត្តាសេដ្ឋកិច្ច គឺមានន័យថាក្រសួងត្រូវកំណត់នូវប្រាក់ខែអប្បបរមាដោយស្របទៅតាមស្ថានភាពសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ន។ ការកំណត់ប្រាក់ឈ្នួលដោយកត្តាសេដ្ឋកិច្ច គឺអាចមានការកើនឡើង ឬ ថយចុះពីមួយឆ្នាំទៅមួយឆ្នាំអាស្រ័យលើការបម្រែបម្រួលនៃសេដ្ឋកិច្ចជាតិ។ ម៉្យាងទៀត ការកំណត់ប្រាក់ឈ្នួលអប្បបរមាក្រសួងទទួលបន្ទុកត្រូវកែសម្រួលទៅតាមដំណាក់កាលនៃការវិវត្តស្ថានភាពសេដ្ឋកិច្ច និង តម្លៃនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ [35] ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៥ កម្រិតផលិតផលដុលក្នុងស្រុក(GDP) នៅកម្ពុជាគឺ ១៨,០៥០លានដុល្លារអាមេរិក ហើយប្រាក់ឈ្នួលអប្បបរមាដែលកម្មករនិយោជិតទទួលបាន គឺ ១២៨ដុល្លារអាមេរិកក្នុង១ខែ[36] ។ ប៉ុន្តែនៅក្នុងឆ្នាំ ២០១៧ កម្រិតផលិតផលដុលក្នុងស្រុក(GDP) នៅកម្ពុជាបានកើនឡើងដល់ ២២,១៦០លានដុល្លារអាមេរិក ដែលការកើនឡើងនោះ រហូតដល់ ២៣% ហើយធ្វើឲ្យប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតកើនឡើងដល់ ១៥៣ ដុល្លារអាមេរិកក្នុងមួយខែ [37] ។ ក្រៅពីនោះទៀត ការកំណត់ប្រាក់ឈ្នួលដោយផ្អែកលើកត្តាសេដ្ឋកិច្ចក្រសួងទទួលបន្ទុកត្រូវតែវិនិច្ឆ័យទៅលើផលិតភាព
ថាតើកម្មករនិយោជិតអាចផលិតផលិតផលក្នុងបរិមាណ ដែលកំណត់ដែរឬទេ ហើយក្រសួងក៏ត្រូវគិតគូរលើភាពប្រកួតប្រជែង និង ទីផ្សារការងារផងដែរ។ មិនតែប៉ុណ្ណោះ

[35] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១០៧

[36] សេចក្តីប្រកាសពត៌មានស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយន ភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា ឆ្នាំ២០១៥, ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤

[37] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និង ផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៧, ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦

ក្រសួងទទួលបន្ទុកក៏ត្រូវគិតគូរទៅលើតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច និង ភាពសមាមាត្រគ្នារវាងផលប្រយោជន៍របស់និយោជិត និង និយោជក ព្រមទាំងស្វែងរកនូវដំណោះស្រាយមួយដែលផ្តល់នូវជីវភាពរស់នៅដល់កម្មករនិយោជិតយ៉ាងណាឲ្យមានលក្ខណៈសមរម្យ និង រក្សានូវផលប្រយោជន៍ដល់និយោជកផងដែរ[38]។

[38] ជា ច័ន្ទមករា និង ហួច ម៉េងហួរ,"ការប្រៀបធៀបប្រាក់ឈ្នួលកម្មករនិយោជិតរវាងប្រទេសកម្ពុជា និង ជប៉ុន",
(សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច,២០១៥), ២៧

# ជំពូកទី២

# នយោបាយប្រាក់ខែ

# ជំពូកទី២៖ នយោបាយប្រាក់ខែ

## ផ្នែកទី១ ការវិវត្តនៃប្រាក់ឈ្នួលពីឆ្នាំ ១៩៩៧ ដល់បច្ចុប្បន្នជាតួលេខ

កម្រិតនៃប្រាក់ឈ្នួលអប្បបរមា គឺមានការប្រែប្រួលរហូតពីមួយឆ្នាំទៅមួយឆ្នាំ ហើយការវិវត្តនៃប្រាក់ឈ្នួលនេះ គឺត្រូវបានឆ្លងកាត់នូវការប្រជុំពិភាក្សារបស់មន្ត្រីទទួលបន្ទុកការងារជាច្រើនលើក រួចសម្រេចដោយការបោះឆ្នោតយកសម្លេងភាគច្រើន។ ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ ២០១៩ នេះ ប្រាក់ ឈ្នួលអប្បបរមានៅកម្ពុជាយើងមានការវិវត្តចំនួន ១៥លើក ដោយការវិវត្តនោះមានការកើនឡើងជា លំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការវិវត្តប្រាក់ឈ្នួលទាំង១៥លើកចំពោះវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងមានដូចខាងក្រោម៖

- លើកទី១
  ក្រសួងសង្គមកិច្ចការងារបានកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កូនជាងហ្វឹកហ្វឺនការងារ ៣០ដុល្លារក្នុងមួយខែ និង សម្រាប់អ្នកដែលបញ្ចប់ការសាកល្បង ៤០ ដុល្លារក្នុង១ខែ[39]។
- លើកទី២ គណៈកម្មការប្រឹក្សាការងារ បានកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសាកល្បងការងារចំនួន ៤០ដុល្លារក្នុង១ខែ និង កម្មករចប់ការសាកល្បង ៤៥ ដុល្លារក្នុង១ខែ ព្រមទាំងទទួលបានថ្លៃបាយចំនួន ១,០០០រៀលក្នុងមួយថ្ងៃ ឬ ដោយឥតគិតថ្លៃសម្រាប់អ្នកធ្វើការថែមម៉ោង និង ប្រាក់រង្វាន់ការងារសម្រាប់អ្នកធ្វើការយូរឆ្នាំ[40]។
- លើកទី៣ គណៈកម្មការប្រឹក្សាការងារ បានកំណត់ប្រាក់ឈ្នួលអប្បបរមា ៤៥ដុល្លារក្នុង១ខែ សម្រាប់កម្មការធ្វើការសាកល្បង និង ៥០ដុល្លារក្នុង១ខែសម្រាប់កម្មករដែលចប់ការសាកល្បង[41]។
- លើកទី៤ គណៈកម្មការប្រឹក្សាការងារ បានសម្រេចផ្តល់នូវប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពទាំងកម្មករសាកល្បង និង

[39] សេចក្តីជូនដំណឹងលេខ ០៦ សកអ, ០៣ មីនា ឆ្នាំ១៩៩៧

[40] សេចក្តីជូនដំណឹងលេខ ០១៧ សកបយ, ១៨ កក្កដា ឆ្នាំ២០០០

[41] សេចក្តីជូនដំណឹងលេខ ៧៤៥ កកបវ, ២៣ តុលា ឆ្នាំ២០០៦

កម្មករចប់ការសាកល្បងការងារចំនួន ៦ដុល្លារក្នុងមួយខែ ដោយមិនបូកបញ្ចូលក្នុងប្រាក់ឈ្នួលគោលទេ[42]។

- លើកទី៥ ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពត្រូវបានបញ្ចូលក្នុងប្រាក់ឈ្នួលគោល ហើយប្រាក់ឈ្នួលអប្បបរមាសរុបសម្រាប់កម្មករនិយោជិតសាកល្បងការងារគឺ ៥៦ ដុល្លារក្នុងមួយខែ (ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៤៥ដុល្លារ បូកប្រាក់តម្លើង ៥ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ដុល្លារ ស្មើនឹង ៥៦ដុល្លារ) និង ប្រាក់ឈ្នួលអប្បបរមាសរុប សម្រាប់កម្មករនិយោជិតពេញសិទ្ធិគឺ ៦១ដុល្លារក្នុងមួយខែ (ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៥០ដុល្លារ បូកប្រាក់តម្លើង ៥ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ដុល្លារ ស្មើនឹង ៦១ដុល្លារ)[43]។
- លើកទី៦ គណៈកម្មការប្រឹក្សាការងារបានសម្រេចផ្តល់នូវប្រាក់រង្វាន់យ៉ាងតិច ៧ដុល្លារ ក្នុង១ខែ សម្រាប់កម្មករនិយោជិតដែលមកធ្វើការទៀងទាត់តាមចំនួនថ្ងៃ និង ប្រាក់ថ្លៃបាយចំនួន ២០០០រៀល ក្នុងមួយថ្ងៃ ឬ ផ្តល់ជូនដោយឥតគិតថ្លៃក្នុងមួយពេលសម្រាប់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការថែមម៉ោង ព្រមទាំងទទួលបាននូវប្រាក់អតីតភាពការងារតាមរយៈឆ្នាំដែលកម្មករនិយោជិតធ្វើការទៀតផង[44]។
- លើកទី៧ កម្មករនិយោជិតទាំងអស់ទទួលបាននូវប្រាក់ឧបត្ថម្ភថែទាំសុខភាពចំនួន ៥ ដុល្លារក្នុង១ខែ ដោយមិនគិតបញ្ចូលក្នុងប្រាក់ឈ្នួលគោលនោះទេ[45]។
- លើកទី៨ ចំពោះកម្មករនិយោជិតណាដែលនិយោជកមិនបានផ្តល់នូវមធ្យោបាយធ្វើដំណើរ ឬ កន្លែងស្នាក់នៅទេ ពួកគេនឹងទទួលបានប្រាក់ ៧ដុល្លារក្នុង១ខែ សម្រាប់សោហ៊ុយធ្វើដំណើរ និង ថ្លៃស្នាក់នៅ ហើយកម្មករណាដែលមកធ្វើការទៀងទាត់គ្មានអវត្តមានសោះនឹងទទួលបានប្រាក់រង្វាន់ ១០ដុល្លារក្នុង១ខែ[46]។

[42] សេចក្តីជូនដំណឹងលេខ ០៣២/០៨ កប/សជណ, ១៧ មេសា ឆ្នាំ២០០៨

[43] សេចក្តីជូនដំណឹងលេខ ០៤៩/១០ កអ/សជណ, ០៩ កក្កដា ឆ្នាំ២០១០

[44] សេចក្តីជូនដំណឹងលេខ ០៤១/១១ កប/សជណ, ០៧ មីនា ឆ្នាំ២០១១

[45] សេចក្តីជូនដំណឹងលេខ ២០៦ កប/សជណ, ១៣ ធ្នូ ឆ្នាំ២០១១

[46] សេចក្តីជូនដំណឹងលេខ ២៣០ កប/សជណ, ២៥ កក្កដា ឆ្នាំ២០១២

- លើកទី៩ ប្រាក់ឧបត្ថម្ភថៃទាំសុខភាព ៥ដុល្លារត្រូវបូកបញ្ចូលក្នុងប្រាក់ឈ្នួលគោល ហើយប្រាក់ឈ្នួលអប្បបរមាសរុបសម្រាប់កម្មករនិយោជិតសាកល្បងគឺ ៧៥ដុល្លារក្នុង ១ខែ (ប្រាក់ឈ្នួលអប្បបរមា ៥៦ដុល្លារ បូកប្រាក់តម្លើង ១៤ដុល្លារ បូកប្រាក់ឧបត្ថម្ភថៃទាំសុខភាព ៥ដុល្លារ ស្មើនឹង៧៥ដុល្លារ) និង ប្រាក់ឈ្នួលអប្បបរមាសរុបសម្រាប់កម្មករពេញសិទ្ធិគឺ ៨០ដុល្លារក្នុង១ខែ (ប្រាក់ឈ្នួលអប្បបរមា ៦១ដុល្លារ បូកប្រាក់តម្លើង១៤ដុល្លារ បូកប្រាក់ឧបត្ថម្ភថៃទាំសុខភាព៥ដុល្លារ ស្មើនឹង៨០ដុល្លារ)[47]។
- លើកទី១០ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតទាំងអស់ត្រូវបានតម្លើង ចំនួន២០ដុល្លារ
  ដូច្នេះប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតសាកល្បងការងារ គឺ ៩៥ដុល្លារ (៧៥ដុល្លារ បូកប្រាក់តម្លើង ២០ដុល្លារ ស្មើនឹង ៩៥ដុល្លារ) និង សម្រាប់កម្មករពេញសិទ្ធិចំនួន ១០០ដុល្លារ (៨០ដុល្លារ បូកនឹងប្រាក់តម្លើង ២០ដុល្លារ ស្មើនឹង ១០០ដុល្លារ)[48]។
- លើកទី១១ គណៈកម្មការប្រឹក្សាការងារសម្រេចតម្លើងប្រាក់ឈ្នួលអប្បបរមាដល់ កម្មករនិយោជិតទាំងអស់ចំនួន២៨ដុល្លារ ពោលគឺកម្មករនិយោជិតសាកល្បង ការងារទទួលបានប្រាក់ខែសរុប ១២៣ដុល្លារ (៩៥ដុល្លារ បូកបន្ថែម២៨ដុល្លារ ស្មើនឹង ១២៣ដុល្លារ) និង កម្មករនិយោជិតពេញសិទ្ធិចំនួន ១២៨ដុល្លារ (១០០ដុល្លារ បូកបន្ថែម ២៨ដុល្លារ ស្មើនឹង ១២៨ដុល្លារ)[49]។
- លើកទី១២
  គណៈកម្មការប្រឹក្សាការងារបានសម្រេចតម្លើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតពេញសិទ្ធិ ១៣៥ដុល្លារ បូកប្រាក់បន្ថែម ៥ដុល្លារ សរុបគឺ ១៤០ដុល្លារអាមេរិកក្នុង១ខែ

[47] សេចក្ដីជូនដំណឹងលេខ ១០៣ កប/សជណ, ០៩ មេសា ឆ្នាំ២០១៣

[48] ប្រកាសស្ដីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង, លេខ ៣១៧ កប/ប្រក, ចុះថ្ងៃទី៣១ ធ្នូ ឆ្នាំ២០១៣

[49] ប្រកាសស្ដីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើងសម្រាប់ឆ្នាំ ២០១៥, លេខ ២៨៣ កប/ប្រក, ចុះថ្ងៃទី១២ វិច្ឆិកា ឆ្នាំ២០១៤

ហើយចំពោះកម្មករនិយោជិតសាកល្បងការងារទទួលបានប្រាក់ខែអប្បបរមាសរុប ១៣៥ដុល្លារក្នុង១ខែ[50]។

- លើកទី១៣

 គណៈកម្មការប្រឹក្សាការងារបានសម្រេចតម្លើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតពេញសិទ្ធិ ១៤៨ដុល្លារ បូកប្រាក់បន្ថែម ៥ដុល្លារ សរុបគឺ ១៥៣ដុល្លារអាមេរិកក្នុង១ខែ

 ហើយចំពោះកម្មករនិយោជិតសាកល្បងការងារទទួលបាន ប្រាក់ខែអប្បបរមាសរុប ១៤៨ដុល្លារក្នុង១ខែ[51]។

- លើកទី១៤

 គណៈកម្មការប្រឹក្សាការងារបានសម្រេចតម្លើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតពេញសិទ្ធិ ១៦៥ដុល្លារ បូកប្រាក់បន្ថែម ៥ដុល្លារ សរុបគឺ ១៧០ដុល្លារអាមេរិកក្នុង១ខែ

 ហើយចំពោះកម្មករនិយោជិតសាកល្បងការងារទទួលបាន ប្រាក់ខែអប្បបរមាសរុប ១៦៥ដុល្លារក្នុង១ខែ[52]។

- លើកទី១៥

 គណៈកម្មការប្រឹក្សាការងារបានសម្រេចតម្លើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតពេញសិទ្ធិ ១៧៧ដុល្លារ បូកប្រាក់បន្ថែម ៥ដុល្លារ សរុបគឺ ១៨២ដុល្លារអាមេរិកក្នុង១ខែ

 ហើយចំពោះកម្មករនិយោជិតសាកល្បងការងារទទួលបាន ប្រាក់ខែអប្បបរមាសរុប ១៧៧ដុល្លារក្នុង១ខែ[53]។

---

[50] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៦, លេខ ៤០៩/១៥ កប/ប្រក, ចុះថ្ងៃទី ០៨ តុលា ឆ្នាំ២០១៥

[51] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៧, លេខ ៤១៤ កប/ប្រក, ចុះថ្ងៃទី ២៩ កញ្ញា ឆ្នាំ២០១៦

[52] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨, លេខ ៣៩៦ កប/ប្រកខល, ចុះថ្ងៃទី០៥ តុលា ឆ្នាំ២០១៧

[53] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៩, លេខ ៤៦៥ កប/ប្រកខល, ចុះថ្ងៃទី០៥ តុលា ឆ្នាំ២០១៨

យោងតាមការរៀបរាប់ខាងលើ យើងសង្កេតឃើញថាប្រាក់ឈ្នួលអប្បបរមាពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាលំដាប់ដោយសារតែសេដ្ឋកិច្ចជាតិកម្ពុជាមានសន្ទុះកើនខ្លាំង បូករួមនឹងកត្តាសង្គមដែលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានលក្ខណៈល្អប្រសើរជាងមុន ហើយការចំនាយរបស់ប្រជាជនក៏មានការកើនឡើងដែរ ព្រោះផលិតផល និង ទំនិញដែលជាតម្រូវការប្រចាំថ្ងៃរបស់ប្រជាជនមានតម្លៃកើនឡើង ដូច្នេះក្រសួងទទួលបន្ទុកការងារគឺត្រូវតែមានការប្រជុំពិភាក្សាក្នុងការតម្លើងនូវប្រាក់ខែអប្បបរមាដល់កម្មករនិយោជិតទាំងអស់។ ទន្ទឹមនឹងនេះដែរការប្រជុំពិភាក្សាលើការតម្លើងប្រាក់ខែនេះពុំដែលទទួលបាននូវសម្លេងគាំទ្រឯកច្ឆ័ន្ទលើតួលេខណាមួយឡើយ។

ឧទាហរណ៍៖ កិច្ចប្រជុំអាណត្តិទី៨ លើកទី១៣ ធ្វើឡើងនៅទីស្តីការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាអំពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើង ឆ្នាំ២០១៦ គឺភាគីនយោជកនៅរក្សជំហា ១៣៣ដុល្លារក្នុងមួយខែ ហើយភាគីសហាជីពនៅតែរក្សាគោលជំហរ ១៦០ដុល្លារក្នុង១ខែដដែល។ ប៉ុន្តែដោយយោងតាមគោលការណ៍ និង យន្តការដែលឯកភាពគ្នាដោយត្រីភាគី គណៈកម្មការប្រឹក្សាការងារបានបោះ ឆ្នោតជាសម្ងាត់លើតួលេខ៣ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- តួលេខចំនួន ១៣៣ដុល្លារអាមេរិក ទទួលបានសម្លេងឆ្នោត ០ លើ ២៨
- តួលេខចំនួន ១៣៥ដុល្លារអាមេរិក ទទួលបានសម្លេងឆ្នោត ២៤ លើ ២៨
- តួលេខចំនួន ១៦០ដុល្លារអាមេរិក ទទួលបានសម្លេងឆ្នោត ២ លើ ២៨
- និងសម្លេងមិនបានការចំនួន ២ លើ ២៨

ក្រោយទទួលបាននូវលទ្ធផលបោះឆ្នោតខាងលើហើយ គណៈកម្មការប្រឹក្សាការងារបានស្នើតួលេខចំនួន ១៣៥ដុល្លារអាមេរិក ជូនឯកឧត្តមក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីធ្វើការសម្រេចចិត្ត។ ជាលទ្ធផល យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈសម្រេចផ្តល់នូវប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតចំនួន

១៣៥ដុល្លារ បូកបន្ថែមនឹងប្រាក់ថៃទាំសុខុមាលភាព និងជីវភាពរស់នៅសមរម្យចំនួន ៥ដុល្លារទៀត សរុបគឺ ១៤០ដុល្លារអាមេរិកក្នុង១ខែ[54]។

មិនតែប៉ុណ្ណោះ នៅក្នុងសង្គមបច្ចុប្បន្នគឺមានការមិនពេញចិត្តរបស់កម្មករនិយោជិតទៅលើប្រាក់ខែរបស់ពួកគេជាច្រើនករណី ដែលការជំទាស់សុំតម្លើងប្រាក់ខែនេះគឺឈានទៅដល់ការធ្វើបាតុកម្មតវ៉ាទាមទារឲ្យនិយោជកតម្លើងប្រាក់ខែសមស្របដល់ពួកគេ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៣ កម្មកររោងចក្ររាប់ម៉ឺននាក់ជាច្រើនរោងចក្រ បានឈប់ពីការងារដើម្បីដង្ហែរក្បួនធ្វើបាតកម្មទាមទារឲ្យតម្លើងប្រាក់ឈ្នួលគោល ១៦០ដុល្លារក្នុងមួយខែ។ ការដង្ហែរក្បួនបាតកម្មនេះត្រូវបានធ្វើឡើងនៅថ្ងៃទី ២៦ ធ្នូ ឆ្នាំ២០១៣ ហើយក្បួនដង្ហែរនេះបានធ្វើឡើងពីជាយក្រុងឆ្ពោះទៅកាន់រាជធានីភ្នំពេញតម្រង់ទៅកាន់ទីស្នាក់ការសមាគមន៍ថៅកែរោងចក្រកាត់ដេរ(GMAC)។ ក្រៅពីនោះទៀត នៅថ្ងៃដដែលក៏មានការធ្វើកូដកម្មតាមបណ្តាខេត្តផ្សេងៗទៀតដែរសរុបជិត ១០រោងចក្រ ដោយពួកគេមិនធ្វើការហើយឈរធ្វើកូដកម្មនៅខាងមុខរោងចក្ររបស់ពួកគេ[55]។ ក្រោយមកទៀត នៅឆ្នាំ២០១៤ ក៏មានទាមទារផ្សេងទៀត ធ្វើឡើងនៅថ្ងៃទី ២៦ កញ្ញា ឆ្នាំ២០១៤ ដោយក្រុមសហជីពរបស់លោក អាត់ ធន់ គឺសហជីពស៊ីវខាវឌូ (C-CAWDU) ដែលបានប្រជុំសម្រេចយកប្រាក់ ១៧៧ដុល្លារ ជាប្រាក់ឈ្នួលគោលជូនដល់កម្មករដាក់ទៅជដែកនឹងភាគីពាក់ព័ន្ធគឺនិយោជក។ ម៉្យាងទៀត តំណាងសហជីពរោងចក្រកាត់ដេរជាង ១០០រោងចក្រនៅភ្នំពេញ និង បណ្តាខេត្តនានាដូចជា ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ និង ខេត្តព្រះសីហានុ ក៏បានព្រមព្រៀងគ្នាកំណត់ទាមទារសុំតម្លើងប្រាក់ឈ្នួលគោលជូនកម្មករ ១៧៧ដុល្លារដូចគ្នាដែរ[56]។

---

[54] សេចក្តីប្រកាសពត៌មានស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និង ផលិត ស្បែកជើងនៅកម្ពុជាសម្រាប់ឆ្នាំ២០១៦, ចុះថ្ងៃទី ០៨ តុលា ឆ្នាំ២០១៥

[55] RFI សម្លេងពិភពលោក,"កម្មករកាន់តែច្រើនធ្វើការតវ៉ាតម្លើងប្រាក់ខែ១៦០ដុល្លារ", http://km.rfi.fr/employee-demonstration-around-cambodia (ចូលទស្សនាថ្ងៃទី០៩ ឧសភា ឆ្នាំ២០១៩)

[56] ខ្មែរ សារិកា,"ក្រុមសហជីពអាត់ ធន់ កំណត់ប្រាក់ឈ្នួល១៧៧ដុល្លារដល់កម្មករ", https://khmersahrika.com/2015/06/21/%e1%9e%80%e1%9f%92%e1%9e%9a%e1%9e%bb%e1%9e%98%e2%80%8b%e1%9e%9f%e1%9e%a0%e1%9e%87%e1%9e%b8%e1%9e%96%e2%80%8b%e1%9e%9b%e1%9f%84%e1%9e%80-%e1%9e%a2%e1%9e%b6%e1%9e%8f%e1%9f%8b-%e1%9e%92%e1%9e%93%e1%9f%8b/ , (ចូលទស្សនា ថ្ងៃទី០៩ ឧសភា ឆ្នាំ២០១៩)

## ផ្នែកទី២ វិធីនៃការកំណត់ប្រាក់ខែដែលត្រូវគោរព

### ២.១. វិធានដែលទាក់ទងទៅនឹងប្រាក់ខែអប្បបរមា

រាជរដ្ឋាភិបាលបាននឹងកំពុងគិតគូរជាខ្លាំងចំពោះជីវភាពរបស់បងៗកម្មករនិយោជិត ដោយរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានសម្រេចដោយបន្ថែមទឹកប្រាក់ចំនួន៥ដុល្លារអាមេរិកលើទឹកប្រាក់ចំនួន ១៧៧ដុល្លារអាមេរិក ដែលត្រូវបានស្នើឡើងដោយគណៈកម្មការប្រឹក្សាការងារ ជាប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និង ផលិតស្បែកជើងក្នុងមួយខែសម្រាប់ឆ្នាំ២០១៩។ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៩ ត្រូវបានកំណត់ជាផ្លូវការនូវទឹកប្រាក់ចំនួន ១៨២ដុល្លារអាមេរិកក្នុងមួយខែ[57]។ បន្ថែមពីនេះទៀតចំពោះកម្មករនិយោជិតសាកល្បងនឹងទទួលបានប្រាក់ឈ្នួលចំនួន១៧៧ដុល្លារអាមេរិកក្នុងមួយខែ ចប់រយៈពេលសាកល្បងនឹងតម្លើងឲ្យ ទទួលបានប្រាក់ឈ្នួលអប្បបរមាចំនួន ១៨២ ដុល្លារអាមេរិក្នុងមួយខែ។ រីឯកម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលគិតតាមបរិមាណផលិតផលត្រូវទទួលបានប្រាក់ឈ្នួលជាក់ស្តែង បើសិនជាប្រាក់ឈ្នួលនៃការផលិតនោះតិចជាង ១៧៧ដុល្លារអាមេរិកនោះ នឹងត្រូវបន្ថែមឲ្យគ្រប់១៧៧ដុល្លារអាមេរិកចំពោះកម្មករនិយោជិតសាកល្បង និង ១៨២ដុល្លារអាមេរិកចំពោះកម្មករនិយោជិតពេញសិទ្ធិ ប៉ុន្តែប្រសិនបើការផលិតបានលើសប្រាក់ឈ្នួលដែលបានកំណត់នោះ គឺត្រូវទទួលបានតាមចំនួនលើសនោះ[58]។

### ២.២. គោលការណ៍សមភាពនៃលាភការណ៍រវាងស្ត្រី និងបុរស

ចំពោះស្ត្រី និងបុរស ការទទួលបាននូវលាភការណ៍វិញគឺត្រូវទទួលបានស្មើគ្នា ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជាយើង។ ស្ត្រី និង បុរសត្រូវផ្អែកទៅលើសមភាពយ៉េនដ័រ គឺមានភាពស្មើមុខស្មើមាត់គ្នាទាំងទៅលើការធ្វើកិច្ចការងារ និងការទទួលបានមកនូវលាភការណ៍ដូចជាប្រាក់ឈ្នួលជាដើម។ យោងតាមច្បាប់ការងារ មាត្រា១០៦ បានចែងថាចំពោះការងារដែលមានលក្ខខណ្ឌស្មើគ្នា ភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈ និង

[57] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសម្រាប់ឆ្នាំ២០១៩ ,០៥ តុលា ២០១៨, ប្រការ១

[58] ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសម្រាប់ឆ្នាំ២០១៩ ,០៥ តុលា ២០១៨, ប្រការ២

ផលដែលធ្វើបានស្មើគ្នាប្រាក់ឈ្នួលត្រូវឲ្យស្មើគ្នាដល់កម្មករនិយោជិតទាំងអស់ដែលស្ថិតនៅក្រោមឱវាទច្បាប់នេះ ទោះបីមានដើមកំណើត ភេទ និងអាយុយ៉ាងណាក៏ដោយ[59]។

### ២.៣. ការមិនរើសអើង(ជាអាទិ៍សហជីព)

រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ធានាអោយប្រជាពលរដ្ឋខ្មែរទាំងពីរភេទទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នាចំពោះមុខច្បាប់។

- ការមិនរើសអើង៖ គ្មាននិយោជកណាម្នាក់អាចយកបញ្ហាពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ឬ ជំនឿ គំនិតនយោបាយ ជាតិកំណើត ដើមកំណើតសង្គម និងការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬ ធ្វើសកម្មភាពក្នុងសហជីព ដើម្បីជាលេសក្នុងការធ្វើសេចក្ដីសំរេចអំពីការជួល ការបែងចែកការងារ ការបណ្ដុះបណ្ដាល វិជ្ជាជីវៈ ការតម្លើងថ្នាក់ ការតម្លើងឋានន្តរសក្តិ ការផ្ដល់កំរៃ ការផ្ដល់អត្ថប្រយោជន៍ និង វិស័យ ឬ ការផ្ដាច់កិច្ចសន្យាការងារ[60]។
- ការរើសអើងដែលអាចអនុញ្ញាតបាន គឺនិយោជកត្រូវតែធ្វើសេចក្តីសំរេចខាងលើដោយផ្អែកលើភាពសមហេតុផល និងដោយមិនផ្អែកលើកត្តាដូចជា ពូជសាសន៍ ភេទ សាសនា ឬ ចូលរួមក្នុងសកម្មភាពនយោបាយ។ ប៉ុន្តែនៅពេលដែលលក្ខណៈនៃការងារតម្រូវលើលក្ខណៈសម្បត្តិសំរាប់មុខរបរ ការរើសអើងនេះត្រូវបាន អនុញ្ញាត[61]។
- ប្រាក់ឈ្នួលត្រូវស្មើគ្នាចំពោះការងារដូចគ្នា៖ ប្រាក់ឈ្នួលផ្សេងគ្នាដោយផ្អែកលើដើមកំណើត ភេទ ឬ អាយុរបស់កម្មករនិយោជិតត្រូវបានហាមឃាត់[62]។

## ផ្នែកទី៣ លក្ខណៈវិនិច្ឆ័យដែលមូលដ្ឋានក្នុងការបង្កើតនយោបាយប្រាក់ខែ

### ៣.១. លក្ខណៈវិនិច្ឆ័យសង្គម

កថាខណ្ឌទី៣ នៃមាត្រា១០៧ នៃច្បាប់ស្តីពីការងារ ដែលស្របតាមមាត្រស ៣នៃអនុសញ្ញាលេខ ១៣១ ស្ដីពីការកំណត់ប្រាក់ឈ្នួលអប្បបរមារបស់អង្គការអន្តរជាតិខាងការងារ (ILO) ឆ្នាំ១៩៧០ កំណត់ថា ធាតុផ្សំដែលត្រូវយកមកគណនាប្រាក់ឈ្នួលអប្បបរមា

[59] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១០៦

[60] រដ្ឋធម្មនុញ្ញ មាត្រា ៣១, ១៣ កក្កដា ២០០៤

[61] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១២

[62] ច្បាប់ការងារ, លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧, មាត្រា ១០៦ សេចក្ដីបង្គាប់អាជ្ញាកណ្ដាល ១៤/០៤ និង ១៨៥/១២(២)

ត្រូវមានយ៉ាងហោចណាស់កត្តាធំៗពីរគឺ កត្តាសង្គម និង កត្តាសេដ្ឋកិច្ច។ ក្នុងលក្ខណៈវិនិច្ឆ័យសង្គមត្រូវមើលទៅលើចំណុចសំខាន់ៗ៣គឺ ស្ថានភាពគ្រួសារ អត្រាអតិជរណា និង ការចំណាយក្នុងការរស់នៅ។ តាមរយៈទិដ្ឋភាពនៃសង្គមបច្ចុប្បន្ន យើងអាចមើលឃើញថាលំហូរនៃអ្នកវិនិយោគដែលចូល មក ធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជាយើងភាគច្រើន គឺវិនិយោគក្នុងវិស័យវាយនភណ្ឌ ទន្ទឹមនឹងនោះដែរអ្នកវិនិយោគភាគច្រើនជាជនជាតិចិន។ ពិតប្រាកដណាស់ការចូលមកបើកក្រុមហ៊ុននៅក្រៅ ស្រុកដែលមិនមែនជាប្រទេសនៃសញ្ជាតិកំណើតផ្ទាល់ខ្លួន វាពិតជាមានភាពលំបាកលំបិនជាខ្លាំង ហើយអ្វីដែលសំខាន់បំផុតខ្វះពុំបាន ដែលអ្នកវិនិយោគភាគច្រើនជួបប្រទះនោះ គឺការទំនាក់ទំនងដែលការទាក់ទងនេះទៅនឹងភាសាដែលត្រូវប្រើប្រាស់ចាំបាច់ជាប្រចាំថ្ងៃ។ ទោះបីជាជួលបុគ្គលិក ដែលជាជនជាតិនៃប្រទេសដែលយើងបានបើកក្រុមហ៊ុនវាមានភាពងាយស្រួលជាង ទាំងការជ្រើស រើស និង ប្រាក់ឈ្នួលទាបជា ងការជួលបុគ្គលិកដែលមានសញ្ជាតដូចគ្នាទៅនឹងអ្នកវិនិយោគក៏ដោយចុះ ក៏អ្នក វិនិយោគភាគច្រើន តែងតែមានជួលនូវកម្មករដែលជាជនជាតិដូចពួកគេដើម្បីមានភាព ងាយស្រួលក្នុងការទំនាក់ទំនងការងារជាពិសេសគឺភាសានិយាយតែម្តង ហើយកម្មករបរទេសភាគច្រើន មានតំណែងខ្ពស់ជាងកម្មករជាតិរបស់យើង។ មកដល់ត្រង់នេះវាបានលិចឡើងនូវសំណួរមួយចោទ សួរថាហេតុអ្វីបានជាកម្មករជាតិ និង កម្មករបរទេសទទួលបានប្រាក់ឈ្នួលក្នុងតម្លៃខុសគ្នា? ចម្លើយ ងាយៗដែលអាចឆ្លើយតបនឹង សំនួរនេះបានគឺ ចំណេះដឹង ជំនាញ និង ការទុកចិត្តជាកត្តាចម្បងដែលធ្វើឲ្យមានការបែងចែងបែបនេះ។ បើយើងងាកមកមើលពីចំណេះជំនាញរវាងកម្មករបរទេស និង កម្មករជាតិ យើងអាចនិយាយបានថាជំនាញរបស់កម្មករជាតិនូវមានកំរិតបើធៀបទៅនឹងកម្មករបរទេសរបស់គេ ទើបកម្មករជាតិ ទទួលបាន ប្រាក់ឈ្នួលទាបជាងបែបនេះ។ ទាក់ទិនទៅនឹងសមត្ថភាពការងារនេះ ទោះបីជាកម្មករខ្មែរយើងមានសមត្ថភាពខ្ពស់ស្មើនឹងកម្មករបរទេសក៏ដោយ ក៏និយោជកផ្តល់ប្រាក់ខែដល់កម្មករបរទេស ច្រើនជាង ខ្មែរដែរ ដោយសារតែអ្នកវិនិយោគទុនក្នុង ប្រទេសកម្ពុជាយើងភាគច្រើនជាជនជាតិបរទេស ដូច្នេះហើយពួកគេតែងតែឲ្យតម្លៃទៅលើជនជាតិ ពួកគេជាងជនជាតិខ្មែរយើង ហើយម្យ៉ាងទៀតនិយោជក ក៏ដូចជាអ្នកវិនិយោគទុនបរទេសទាំងនោះ

ក៏មានសេចក្តីទុកចិត្តលើសមត្ថភាពការងារកម្មករបរទេស ជាងកម្មករខ្មែរដែរ ដែលទាំងនេះគឺជាផលវិបាកយ៉ាងធ្ងន់ធ្ងរចំពោះកម្មករខ្មែរ។ ដោយមើលឃើញថា បងៗកម្មករនិយោជិតជួបប្រទះនៅស្ថានភាពគ្រួសារដែលមានភាពលំបាកលំបិនខ្លាំង ទើបជំរុញឲ្យពួកគាត់ចំណាក់ស្រុកមកធ្វើការងារដើម្បីផ្គត់ផ្គង់នូវជីវភាពគ្រួសារ។ ហើយដោយមើលឃើញថា កំណើននៃអត្រាអតិផរណាមានការកើនឡើយ គឺទំនិញមានតម្លៃថ្លៃចំណែកឯតម្លៃនៃទឹកប្រាក់បាន តម្លៃទាបជាង ទើបធ្វើឲ្យជួបនូវផលវិបាកចំពោះកម្មករនិយោជិត។ នឹងមើលទៅលើការចំណាយក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគាត់និងមានបកស្រាយនៅក្នុងចំណុច៣.១.២ ខាងក្រោមនេះផងដែរ។

**៣.១.១ និយមន័យនៃតម្រូវការ**

តម្រូវការ ជាទំនាក់ទំនងផ្ទុយគ្នារវាងថ្លៃទំនិញXមួយទៅនិងបរិមាណទំនិញXនោះដែលអ្នកទិញចង់ និង មានលទ្ធភាពទិញក្នុងរយៈពេលមួយជាកំណត់ដោយលក្ខខ័ណ្ឌដទៃទៀតមិនប្រែប្រួល។

ច្បាប់តម្រូវការបានចែងថា ប្រសិនបើកត្តាដទៃទៀតនៅថេរដដែល ហើយថ្លៃទំនិញXមួយកើនឡើងនាំឲ្យបរិមាណទំនិញXនោះថយចុះនិងច្រាសមកវិញ[63]។

**៣.១.២ ការវាយតម្លៃនៃតម្រូវការ**

តាមរយៈលំហូរចូលមកនៃអ្នកវិនិយោគទុនបរទេស ដែលបានមកវិនិយោគនៅក្នុងប្រទេសកម្ពុជា ទើបធ្វើឲ្យប្រទេសនេះពោរពេញទៅដោយការជ្រើសរើសបុគ្គលិក និង ការដាក់ពាក្យធ្វើការដែលនេះបញ្ជាក់បានថាតម្រូវការការងារកើនឡើង។ បើទោះបីជាតម្រូវការមានច្រើនដែលអាចធ្វើឲ្យជីវភាពប្រជាជនកម្ពុជាមានការប្រសើរឡើងបន្តិចក៏ដោយ ក៏មានជួបនូវឧបសគ្គខ្លះក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ បើងាកមកមើលពីការចាយវាយប្រចាំថ្ងៃរបស់កម្មករនិយោជិតមួយចំនួនវិញមិនសមាមាត្រជាមួយនឹងប្រាក់ឈ្នួលដែលទទួលបានក្នុងមួយខែការងារទេ។ ដោយកម្មករនិយោជិតខ្លះត្រូវចំណាកស្រុកមកធ្វើការងារនៅឆ្ងាយផ្ទះ ដូចនេះប្រាក់ឈ្នួលដែលទទួលបានត្រូវចំណាយទៅលើឈ្នួលផ្ទះ ចំណាយទៅលើម្ហូបអាហារប្រចាំថ្ងៃ ថ្លៃទឹកភ្លើង និង ចំណាយទៅលើការធ្វើដំណើរ នេះបើ

63 https://l.facebook.com/l.php?u=http%3A%2F%2Febooks.libraryrule.com%2Fimages%2Fpdf_file_item%2F1484ecc5902d3210a6829081388820cf.pdf%3Ffbclid%3DIwAR2a0xxuxMjOi958p3RpQ6vKKAwyQO6t2O78-gT5v01YwgEe3h3q4lIRWDo&h=AT2yx-WFDJQVGeKu2Jx3fdfjhHaF753ay0Mk5LWqv8_C4jmmxJo-i4c6mjhJLu-WfEVerio71TVC3sU2Y_Nj5WXgIL6n548045fgY7SvCXfkW5UroGRgqibNQ5NOBdyYR99KfQ

យោងតាមការសម្ភាសន៍រវាងកម្មករនិយោជិតនៃរោងចក្រសិប្បកម្មកាត់ដេរកូនខ្មែរ ដែលមានទីតាំងនៅភូមិព្រៃព្រីង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយគាត់បានរៀបរាប់ថាក្នុង១ខែគាត់ត្រូវចំណាយទៅលើថ្លៃផ្ទះចំនួន៤០$-៥០$ ចំណែកថ្លៃទឹកភ្លើងវិញចំនួន ១៥$-២០$ ឯក្នុងការ ធ្វើដំណើរវិញ គាត់អាចជ្រើសរើសយកឡានជួលសម្រាប់ដឹកកម្មករទៅមកដែលត្រូវចំណាយយ៉ាង តិច១០$ក្នុងមួយខែ ហើយចុងក្រោយនោះគឺអាហារប្រចាំថ្ងៃរបស់ពួកគាត់ជាមធ្យមត្រូវចំណាយលុយចំនួន៧០០០៛ ទៅ៨០០០៛ បើគិតជាសរុបក្នុងមួយខែពួកគាត់ត្រូវចំណាយសរុបប្រមាណជាង ២១០០០០៛ ទៅ ២៤០០០០៛ នេះមិនរាប់បញ្ចូលនូវសម្ភារៈសម្រាប់តុបតែងលំអដែលកម្មករនិយោជិត
ជានារីត្រូវការប្រើប្រាស់ជាប្រចាំផង។ ដូចនេះ យើងអាចមើលឃើញហើយថាប្រាក់ចំនូលដែលកម្មករនិយោជិតទទួលបានក្នុងមួយខែៗនោះវាសឹងតែគ្មានសល់នោះទេ ណាមួយត្រូវផ្ញើទៅឲ្យអ្នកផ្ទះនៅឯស្រុកកំណើត ណាមួយត្រូវការចំណាយផ្ទាល់ខ្លួនទៀត។ ចំណែកឯថ្លៃទំនិញក៏មានភាពកើនឡើងបន្ថែមទៀតទើបធ្វើឲ្យកម្មករនិយោជិតមានការលំបាកក្នុងការចាយវាយ។

### ៣.២. លក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ច

យើងបានដឹងហើយថាការកំណត់ប្រាក់ខែរបស់កម្មករនិយោជិតគឺត្រូវពឹងផ្អែកទៅលើកត្តា ២ គឺកត្តាសង្គម និង កត្តាសេដ្ឋកិច្ច ដូច្នេះហើយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលទទួលបន្ទុកការងារ ក្រៅពីសិក្សាទៅលើលក្ខណៈវិនិច្ឆ័យសង្គមហើយ ក៏ត្រូវវិភាគទៅលើលក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ចដែរ ដើម្បីបង្កើតនូវនយោបាយប្រាក់ខែ។

#### ៣.២.១ ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា

ប្រទេសកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍន៍ដែលស្ថិតក្នុងកម្រិតទាប ហើយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមួយចំនួនធំក៏កំពុងមានភាពលំបាក ដោយសារកង្វះខាតការងារ ក៏ដូចជាភាពមិនគ្រប់គ្រាន់នៃប្រាក់ឈ្នួលដែលពួកគេទទួលបាន។ ក៏ប៉ុន្តែទន្ទឹមនឹងភាពអន់ថយនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានព្យាយាមស្តារសេដ្ឋកិច្ចនៃប្រទេសកម្ពុជាឲ្យជៀសផុតពីភាពក្រីក្រនេះដែរ ដោយជាក់ស្តែង នៅឆ្នាំ ២០១២ អត្រាភាពក្រីក្របានធ្លាក់ចុះដល់ ១៨.៦% ពោលគឺធ្លាក់ចុះ ១.៩% ធៀបនឹងអត្រាភាពក្រីក្រក្នុងឆ្នាំ ២០១១។ ម៉្យាងទៀត ក្បាលម៉ាស៊ីនចំបងក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា គឺ វិស័យកាត់ដេរសម្លៀកបំពាក់ ហើយកត្តាជម្រុញកំណើនសេដ្ឋកិច្ចសំខាន់បំផុតលំដាប់ទី២ គឺវិស័យសំណង់។ ចំពោះវិស័យកាត់ដេរសម្លៀកបំពាក់បានរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំចំនួន ១៤.១ ភាគរយគិតចាប់ពីពាក់កណ្តាលឆ្នាំ ២០១៤ មក។ រីឯវិស័យសំណង់ និង

វិស័យសេវាកម្មក៏មានសន្ទុះកើនឡើងដែរ

ទោះបីជាអត្រាកំណើននៃការមកដល់នៃភ្ញៀវទេសចរណ៍មានល្បឿនយឺតធៀបនឹងឆ្នាំ ២០១៣ ៥.២% ក៏ដោយ[64]។ មិនតែប៉ុណ្ណោះ ដូចដែលបានរៀបរាប់ខាងលើគឺកម្រិតផលិតផលដុលក្នុងស្រុក (GDP) នៅកម្ពុជាមានការកើនឡើង ជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយការកើនឡើងនេះផ្អែកទៅលើកំណើននៃវិស័យវាយនភ័ណ្ឌ និងកាត់ដេរ វិស័យសេវាកម្ម និង វិស័យកសិកម្ម ព្រមទាំងការកើនឡើងនូវតម្រូវការក្នុងស្រុក និង ការនាំចេញទៅក្រៅប្រទេស។ ឧទាហរណ៍៖ នៅក្នុងឆ្នាំ ២០១២ សេដ្ឋកិច្ចប្រទេសកម្ពុជាបានកើនឡើង ៧.៣% ដែលធ្វើឲ្យកម្រិតផលិតផលដុលក្នុងស្រុក (GDP) ក្នុងឆ្នាំនោះកើនដល់ ១៤,០៥០លានដុល្លារអាមេរិក ហើយវិស័យដែលចូលរួមចំនែកក្នុងការកើនឡើងនេះ គឺមានវិស័យសេវាកម្ម ៤១%, វិស័យវាយនភ័ណ្ឌ និង កាត់ដេរ ៣២% និង វិស័យកសិកម្ម ២៧%។ ចំពោះវិស័យវាយនភណ្ឌ និង កាត់ដេរនៅក្នុងឆ្នាំ ២០១២ មានការនាំចេញទៅក្រៅប្រទេសច្រើនជាងគេរហូតទៅដល់ ៧២% នៃការនាំចេញសរុប ហើយចំពោះការនាំចូលផ្នែក វាយនភណ្ឌ កាត់ដេរ និងសម្លៀកបំពាក់នេះក៏មានកម្រិតខ្ពស់ជាងផ្នែកដទៃទៀតដែរ

ដើម្បីបំពេញតម្រូវការប្រជាជនក្នុងស្រុក និង ប្រើប្រាស់ជាវត្ថុធាតុដើមផ្សេងៗ[65]។ ក្រៅពីនេះទៀត កម្រិតនៃការនាំចេញផ្នែកកាត់ដេរ និង សម្លៀកបំពាក់នៅតែបន្តកើនឡើងរហូតដល់ ពាក់កណ្ដាលឆ្នាំ២០១៨ ចំនួន ១៦.១% ដែលធ្វើឲ្យកម្រិតផលិតផលដុលក្នុងស្រុក (GDP) ធៀបនឹងឆ្នាំ២០១៧ បានកើនឡើង ៦.៨% [66] ។ ទន្ទឹមនឹងការកើនឡើងផ្នែកសេដ្ឋកិច្ចនេះ ក៏ធ្វើឲ្យប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតកើនឡើងដល់ ១៧០ដុល្លារអាមេរិកក្នុង១ខែ បើធៀបនឹងឆ្នាំ ២០១៧ គឺកើនឡើង ១១%។

[64] "ទំព័រស្ដីពីប្រទេសកម្ពុជានិងសូចនាករសំខាន់ៗ", https://www.worldbank.org/content/dam/Worldbank/document/EAP/cambodia/Cambodia_EAP_Update-Oct2014_KH.pdf (ចូលទស្សនាថ្ងៃទី១០ ឧសភា ឆ្នាំ២០១៩)

[65] OECD, "Structural Policy Country Notes Cambodia" [គោលនយោបាយតម្លាភាពប្រទេសកម្ពុជា], https://www.oecd.org/site/seao/Cambodia.pdf (ចូលទស្សនាថ្ងៃទី១០ ឧសភា ឆ្នាំ២០១៩)

[66] World Bank, "Recent Economic Developments and Outlook" [ការអភិវឌ្ឍសេដ្ឋកិច្ចនិងទស្សនវិស័យថ្មីៗ], https://www.worldbank.org/en/country/cambodia/publication/cambodia-economic-update-october-2018-recent-economic-developments-and-outlook (ចូលទស្សនាថ្ងៃទី១០ ឧសភា ឆ្នាំ២០១៩)

## ៣.២.២ មូលហេតុដែលធ្វើឲ្យប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាទាបជាងប្រទេសដទៃ

យើងបានឃើញហើយថាសេដ្ឋកិច្ចនៃប្រទេសកម្ពុជាយើង គឺមានសន្ទុះកើនឡើងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែប្រសិនជាយើងធ្វើការប្រៀបធៀបទៅនឹងប្រទេសកូរ៉េខាងត្បូងដែលជាប្រទេសអភិវឌ្ឍ យើងឃើញថាសេដ្ឋកិច្ចយើងនៅមានកម្រិតអន់ថយខ្លាំងដោយកម្រិតផលិតផលដុលក្នុងស្រុក (GDP) នៅកូរ៉េខាងត្បូងក្នុងឆ្នាំ ២០១៧ ស្មើនឹង ១,៥៣១,០០០លានដុល្លារអាមេរិក ដែលខ្ពស់ជាង GDP ប្រទេសកម្ពុជាខ្លាំង ហើយចំនែកឯប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកកាត់ដេរសម្លៀកបំពាក់ គឺស្មើនឹង ១,០៣២ដុល្លារអាមេរិកក្នុង១ខែ[67] ដែលខ្ពស់ជាងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតនៅកម្ពុជាស្មើតែ១០ដង។ ម៉្យាងវិញទៀតបើយើងមើលទៅកម្រិតផលិតផលជាតិដុល (GNP) រវាងប្រទេសទាំងពីរក៏មានកម្រិតខុសគ្នាខ្លាំងដែរ ដោយ GNP នៅប្រទេសកម្ពុជាគឺ ៦០,១២០ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៧ រីឯប្រទេសកូរ៉េខាង ត្បូងវិញកម្រិត GNP គឺកម្រិតដល់ទៅ ១,៩៦៩,០០០លានដុល្លារអាមេរិក ដែលនេះបញ្ជាក់ឲ្យឃើញថាផលិតផលកម្ពុជាដែលផលិតទាំងក្នុង និង ក្រៅស្រុកនៅមានកម្រិតទាបនៅឡើយបើធៀបទៅនឹង ប្រទេសកូរ៉េខាងត្បូងដែលជាប្រទេសអភិវឌ្ឍ និង មានភាពរីកចម្រើនខ្លាំងខាងផ្នែកសេដ្ឋកិច្ច។ កត្តាដែលធ្វើឲ្យមានភាពខុសគ្នាខ្លាំងរវាងប្រទេសទាំងពីរនេះ គឺមានដូចជាកត្តាសុខភាព ការសិក្សា វិសមភាពក្នុងសង្គម សន្តិសុខសង្គម ការជួញដូរនិងលំហូរហិរញ្ញវត្ថុ និង និរន្តរភាពសេដ្ឋកិច្ចសង្គម។

### ក. កត្តាសុខភាព

សម្រាប់ប្រទេសកម្ពុជាអត្រាមរណភាពជាមធ្យមនៅអាយុ ៦៩ឆ្នាំ ហើយនៅកូរ៉េខាងត្បូងនៅអាយុ ៨២ឆ្នាំ ដោយក្នុងនោះអត្រាមរណៈរបស់ស្ត្រីនៅកម្ពុជាគឺ ១៣៩នាក់ក្នុងចំណោម១០០០នាក់ដែលស្មើនឹង១៣.៩% រីឯអត្រាមរណៈរបស់បុរសគឺ ២០៥នាក់ក្នុងចំណោម១០០០នាក់ដែលស្មើនឹង២០.៥%។ ប៉ុន្តែសម្រាប់នៅប្រទេសកូរ៉េខាងត្បូងវិញ អត្រាមរណៈរបស់ស្ត្រីគឺ ៣៧នាក់ក្នុងចំណោម ១០០០នាក់ដែលស្មើនឹង៣.៧% រីឯបុរសវិញ

[67] ILO, "Minimum Wages in the Global Garment Industry" [ប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសកល]https://www.ilo.org/asia/info/research-and-data/WCMS_317002/lang--en/index.htm (ចូលទស្សនាថ្ងៃទី១០ ឧសភា ឆ្នាំ២០១៩)

អត្រាមរណៈគឺ ៨៦នាក់ក្នុងចំណោម ១០០០នាក់ដែលស្មើនឹង៨.៦%។ ក្រៅពីនោះទៀត សម្រាប់អត្រាកុមារក្រោមអាយុ ៥ឆ្នាំដែលខ្វះជីវជាតិ និង លូតលាស់មិនបានល្អរវាងប្រទេសទាំងពីរក៏មានភាពខុសគ្នាខ្លាំងដែរ ដោយភាគរយនៅប្រទេសកម្ពុជាគឺ ៣២.៩% ប៉ុន្តែនៅកូរ៉េខាងត្បូងតែ ២.៥% ប៉ុណ្ណោះ។ កត្តាទាំងនេះហើយ ដែលបញ្ជាក់ពីបញ្ហា សុខភាពរបស់ប្រជាជនកម្ពុជាយើង ដែលជាហេតុធ្វើឲ្យប្រជាជនយើងមួយចំនួនធំមានសុខភាពពុំរឹងមាំ និង ធ្វើឲ្យសមត្ថភាពការងារខ្សោយ ហើយទទួលបាននូវប្រាក់ឈ្នួលមិនគ្រប់គ្រាន់[68]។

### ខ. កត្តាការសិក្សា

នៅប្រទេសកម្ពុជា បើយើងមើលទៅរយៈពេលដែលប្រជាជនបានទទួលការសិក្សាជាមធ្យម ចំនួន ១២ឆ្នាំ ដែលក្នុងនោះយើងសង្កេតឃើញថាប្រជាជនមួយចំនួនធំភាគច្រើននៅតាមជនបទ គឺពុំបានទទួលការសិក្សាបន្តនៅមហាវិទ្យាល័យទេ ដោយសារតែស្ថានភាពគ្រួសារពុំមានលទ្ធភាព គ្រប់គ្រាន់សម្រាប់ការចំនាយថ្លៃសិក្សា ហើយបុគ្គលទាំងនោះក៏ត្រូវចេញទៅប្រកបរបរសម្រាប់ជួយ គ្រួសារទាំងពុំមាននូវចំណេះជំនាញគ្រប់គ្រាន់។ ប៉ុន្តែបើយើងមើលទៅប្រទេសកូរ៉េខាងត្បូងវិញ ប្រជាជនគេទទួលបានការសិក្សាជាមធ្យមរយៈពេល ១៦.៥ឆ្នាំ ដែលទិន្នន័យនេះបញ្ជាក់ឲ្យឃើញថា ប្រជាជនគេភាគច្រើនបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលមានន័យថាពួកគេភាគច្រើនមាន ចំណេះដឹងខ្ពស់ និងបានសិក្សាជំនាញច្បាស់លាស់ក្នុងការធ្វើការ ឬ ប្រកបចិញ្ចឹមជីវិតពួកគេ[69]។ យោងតាមការប្រៀបធៀបរវាងប្រទេសកម្ពុជា និង កូរ៉េខាងត្បូង បង្ហាញឲ្យឃើញថាកម្រិតនៃការសិក្សារបស់ប្រជាជនខ្មែរភាគច្រើននៅមានកម្រិតនៅឡើយ ជាពិសេសសម្រាប់កម្មករតាមរោងចក្រ សហគ្រាសមួយចំនួន គឺពួកគាត់ពុំបានសិក្សាជំនាញច្បាស់លាស់នោះទេ ដែលជាហេតុធ្វើឲ្យពួកគាត់ទទួលបានប្រាក់ខែតិចជាងអ្នកមានជំនាញច្បាស់ និង មិនអាចផ្គត់ផ្គង់ជីវភាពគ្រប់គ្រាន់។

### គ. កត្តាវិសមភាពក្នុងសង្គម

វិសមភាពនៅក្នុងសង្គម គឺជាកត្តាដែលធ្វើឲ្យមនុស្សមានសិទ្ធិពុំស្មើគ្នាទាំងនៅក្នុងវិស័យការ សិក្សា និង វិស័យការងារ។ វិសមភាពនៅក្នុងវិស័យការសិក្សា

---

[68] UNDP, "Human Development Indicators in Cambodia" [សូចនាករអភិវឌ្ឍមនុស្សនៅកម្ពុជា], http://hdr.undp.org/en/countries/profiles/KHM (ចូលទស្សនាថ្ងៃទី១២ ឧសភា ឆ្នាំ២០១៩)

[69] ដូច៦៧

គឺដូចជាភាពខុសគ្នារវាងការសិក្សានៅសាលារដ្ឋ និង សាលាឯកជន ដោយនៅតាមសាលាឯកជនដែលសិស្សត្រូវរៀនបង់លុយភាគច្រើនមាននូវសម្ភារៈសិក្សាច្រើនជាងសាលារដ្ឋដែលរៀនមិនបង់លុយ ហើយចំពោះសាលារដ្ឋវិញ បើសិនជាសិស្សចង់រៀនគួរក្រៅម៉ោងបន្ថែមគឺត្រូវតែបង់លុយសម្រាប់ថ្លៃរៀនគួរ ដូច្នេះទាំងអស់នេះហើយដែលធ្វើឲ្យមានភាពមិនស្មើគ្នានៅក្នុងសង្គមដោយសិស្សដែលគ្មានសមត្ថភាពបង់ថ្លៃសិក្សាមានឱកាសក្នុងការទទួលបាននូវចំណេះដឹងបន្ថែមដូចសិស្សដែលមានសមត្ថភាពបង់ថ្លៃសិក្សា[70] ។ ដោយសារកត្តានេះហើយ ដែលធ្វើឲ្យមាននូវវិសមភាពប្រាក់ខែ មានន័យថារវាងអ្នកមាន និង អ្នកក្រមានគម្លាតខ្លាំង គឺអ្នកខ្លះទទួលបាននូវប្រាក់ច្រើន រីឯអ្នកខ្លះទៀតទទួលបានប្រាក់ខែតិចខ្លាំងស្ទើរតែចិញ្ចឹមខ្លួនឯងមិនរស់។

**ឃ. កត្តាសន្តិសុខសង្គម**

កត្តាសន្តិសុខសង្គម គឺជាផ្នែកមួយដ៏សំខាន់សម្រាប់វិស័យសេដ្ឋកិច្ច ដោយសេដ្ឋកិច្ចអាចនឹងកើន ឬ ថយអាស្រ័យលើសន្តិសុខសង្គមនៃប្រទេសនោះមានស្ថេរភាពដែរឬទេ។ ឧទាហរណ៍៖ បើសិនជាប្រទេសមួយមានស្ថេរភាពផ្នែកសន្តិសុខសង្គម នោះនឹងមានអ្នកវិនិយោគទុនជាច្រើនមកបណ្តាក់ទុននៅក្នុងប្រទេសនោះ ហើយសេដ្ឋកិច្ចនៃប្រទេសនោះនឹងរីកចម្រើន ចំណែកឯកម្រៃប្រាក់ឈ្នួលជាមធ្យមនៅប្រទេសនោះក៏កើនឡើងដែរ។ ប៉ុន្តែបើសិនជាស្ថានភាពសន្តិសុខសង្គមនៅប្រទេសនោះអស្ថេរភាព ឬមានភាពវឹកវរក្នុងសង្គមនោះសេដ្ឋកិច្ចជាតិនៃប្រទេសនោះនឹងធ្លាក់ចុះ ហើយកម្រិតប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតក៏ធ្លាក់ចុះដែរ។ ជាក់ស្តែងបើយើងមើលទៅសន្តិសុខសង្គមនៃប្រទេសកម្ពុជាវិញ ឃើញថាអត្រាមនុស្សឃាតគឺស្មើនឹង ១.៨ ដោយនៅក្នុងនោះអត្រាមនុស្សដែលគ្មានផ្ទះសម្បែងគិតជាមធ្យមក្នុង១ឆ្នាំគឺ ៣៥៦នាក់ក្នុងចំណោម១លាននាក់ និងអត្រាជនភៀសខ្លួនគឺចំនួន ១២,២០០នាក់ក្នុង១ឆ្នាំ[71] ។ ប៉ុន្តែបើយើងមើលទៅប្រទេសកូរ៉េខាងត្បូងវិញ ឃើញថាអត្រាមនុស្សឃាតគឺស្មើនឹង ០.៧ ដោយក្នុងនោះអត្រាមនុស្សដែលគ្មានផ្ទះសម្បែង គិតជាមធ្យមក្នុង១ឆ្នាំគឺត្រឹមតែ

---

[70] Antoine, "Inequality in Education" [វិសមភាពនៅក្នុងវិស័យសិក្សា], https://inequalityproject.wordpress.com/inequality-in-education/?fbclid=IwAR0_4I5dZo518-6gvqhaCqQBKTtdoGZ4y4wIuFC5foLmedekVLmBtGvVyM4 (ចូលទស្សនាថ្ងៃទី១២ ឧសភា ឆ្នាំ២០១៩)

[71] UNDP, "Human Development Indicators in Cambodia" [សូចនាករអភិវឌ្ឍមនុស្សនៅកម្ពុជា], http://hdr.undp.org/en/countries/profiles/KHM (ចូលទស្សនាថ្ងៃទី១២ ឧសភា ឆ្នាំ២០១៩)

៥នាក់ក្នុងចំណោម១លាននាក់ប៉ុណ្ណោះ[72] ។ យោងតាមអត្រាដែលរៀបរាប់ខាងលើបញ្ជាក់ឲ្យឃើញថា ប្រទេសកម្ពុជាយើងពុំសូវមានស្ថេរភាពខាងសន្តិសុខសង្គមនោះទេ ដោយសារតែអត្រាមនុស្សឃាត និង មនុស្សដែលគ្មានផ្ទះសម្បែងខ្ពស់បើធៀបទៅនឹងប្រទេសដែលអភិវឌ្ឍខ្លាំងខាងផ្នែកសេដ្ឋកិច្ច នោះបញ្ជាក់ថាប្រទេសកម្ពុជាពុំទាន់រីកចម្រើនខ្លាំងខាង ផ្នែកសេដ្ឋកិច្ចនោះទេ ដោយសារអ្នកវិនិយោគទុនខ្លះមិនសូវមានទំនុកចិត្តលើប្រទេសយើងនៅឡើយ ដែលជាហេតុធ្វើឲ្យកម្រិតប្រាក់ឈ្នួលអប្បបរមានៅមានចំនួនទាប។

### ខ. កត្តាការជួញដូរ និង លំហូរហិរញ្ញវត្ថុ

ការកើនឡើង ឬ ការថយចុះនៃសេដ្ឋកិច្ចគឺវាអាស្រ័យទៅលើកត្តាច្រើន ហើយក្នុងនោះដែរ កត្តាចម្បងដែលធ្វើឲ្យមានបម្រែបម្រួលសេដ្ឋកិច្ចនោះគឺកត្តាជួញដូរ ដោយធ្វើការនាំចេញទំនិញទៅក្រៅប្រទេស ឬ នាំចូលទំនិញពីក្រៅប្រទេសមកបំពេញតម្រូវការក្នុងស្រុក ហើយព្រមទាំងកត្តាលំហូរហិរញ្ញវត្ថុដោយការវិនិយោគទុនសំណាកអ្នកវិនិយោគទាំងក្នុង និង ក្រៅស្រុក។ ម្យ៉ាងទៀត បើសិនជាមានការកើនឡើងនូវកត្តាទាំងពីរនេះ ក្រៅពីធ្វើឲ្យសេដ្ឋកិច្ចកើនឡើងហើយ វាក៏ធ្វើឲ្យប្រាក់ឈ្នួល របស់កម្មករនិយោជិតកើនឡើងដែរ។ មិនតែប៉ុណ្ណោះ ការដែលមានអ្នកវិនិយោគមកបណ្តាក់ទុន គឺបង្កើតនូវមុខរបរដល់ប្រជាជនខ្មែរឲ្យមានការងារធ្វើ ហើយជៀសផុតពីភាពក្រីក្រ។ ប៉ុន្តែប្រសិនបើ ប្រទេសមួយពុំសូវមានសន្ទុះខាងការជួញដូរ និង លំហូរហិរញ្ញវត្ថុនោះទេ ប្រទេសនោះគឺពុំសូវមានសន្ទុះខាងសេដ្ឋកិច្ចទេ ហើយឱកាសការងារសម្រាប់ប្រជាជនក៏មិនសូវមានច្រើនដែរ។

### ច. និរន្តរភាពសេដ្ឋកិច្ចសង្គម

យើងបានដឹងហើយថា សេដ្ឋកិច្ចនៃប្រទេសមួយរីកចម្រើន គឺអាស្រ័យទៅលើសមត្ថភាពការសិក្សា ការចេះដឹងរបស់ប្រជាពលរដ្ឋ ក៏ដូចជាលទ្ធភាពការងាររបស់កម្មករនិយោជិតទាំងគ្រប់វិស័យ ផងដែរ។ បើសិនជាប្រទេសនោះ កម្មករនិយោជិតមានលទ្ធភាពការងារខ្ពស់ នោះអត្រានៃប្រាក់ឈ្នួល របស់ពួកគេក៏ខ្ពស់ដែរ។ ជាក់ស្តែង បើយើងធ្វើការប្រៀបធៀបនិរន្តរភាពសេដ្ឋកិច្ចសង្គមរវាងប្រទេស កម្ពុជា និង

---

[72] UNDP, "Human Development Indicators in South Korea" [សូចនាករអភិវឌ្ឍមនុស្សនៅកូរ៉េខាងត្បូង], http://hdr.undp.org/en/countries/profiles/KOR (ចូលទស្សនាថ្ងៃទី១២ ឧសភា ឆ្នាំ២០១៩)

ប្រទេសកូរ៉េខាងត្បូង យើងឃើញថា ភាគរយនៃកម្លាំងពលករជំនាញនៅកម្ពុជាគឺស្មើនឹង ៩.៧%នៃកម្លាំងពលករសរុប[73] រីឯប្រទេសកូរ៉េខាងត្បូងវិញ ភាគរយនៃកម្លាំងពលករជំនាញគឺស្មើនឹង ៨៤.៦%នៃកម្លាំងពលករសរុប[74]។ តាមរយៈទិន្នន័យខាងលើនេះ បញ្ជាក់ឲ្យឃើញថាអត្រានៃកម្មករនិយោជិតដែលមានជំនាញនៅមានតិច ហើយសមត្ថភាពការងាររបស់កម្មករខ្មែរនៅមានកម្រិត ដែលនោះហើយជាហេតុដែលធ្វើឲ្យកម្មករនិយោជិតនៅកម្ពុជាទទួលបាននូវប្រាក់ឈ្នួលទាប និងមិនអាច បំពេញនូវតម្រូវការប្រចាំថ្ងៃគ្រប់គ្រាន់។

សរុបមកភាពគ្រប់គ្រាន់ ឬ ភាពខ្វះខាតនៃប្រាក់ឈ្នួលរបស់កម្មករនិយោជិត គឺអាស្រ័យទៅលើស្ថានភាពសេដ្ឋកិច្ច និងសង្គមនៃប្រទេសនោះ ហើយដើម្បីឲ្យអត្រានៃប្រាក់ឈ្នួលរបស់កម្មករនិយោជិតកើនឡើងសមស្របទៅនឹងតម្រូវការប្រចាំថ្ងៃរបស់ពួកគេ យើងទាំងអស់គ្នាត្រូវតែធ្វើការពង្រឹងនូវកត្តាទាំង៦ដូចដែលបានរៀបរាប់ខាងលើនេះ។

[73] UNDP, "Human Development Indicators in Cambodia" [សូចនាករអភិវឌ្ឍមនុស្សនៅកម្ពុជា], http://hdr.undp.org/en/countries/profiles/KHM (ចូលទស្សនាថ្ងៃទី១២ ឧសភា ឆ្នាំ២០១៩)

[74] UNDP, "Human Development Indicators in South Korea " [សូចនាករអភិវឌ្ឍមនុស្សនៅកូរ៉េខាងត្បូង], http://hdr.undp.org/en/countries/profiles/KOR

# សេចក្តីសន្និដ្ឋាន

# និង

# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាអស់រយៈពេល ៤ឆ្នាំ និងតាមការសិក្សាស្រាវជ្រាវរយៈពេល ២ខែចំពោះការសរសេរសារណានេះ យើងឃើញថាការសិក្សាអំពីភាពមិនគ្រប់គ្រាន់នៃប្រាក់ខែរបស់កម្មករនិយោជិត គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់កម្មករគ្រប់រូបមិនថានៅប្រទេសកម្ពុជា ឬ ប្រទេសដទៃនោះទេ។ ម្យ៉ាងទៀត ការសិក្សាអំពីប្រធានបទនេះគឺជួយការពារអត្ថប្រយោជន៍ដល់កម្មករនិយោជិតដែលទទួលរងនូវភាពអយុត្តិធម៌ទាក់ទិននឹងការកេងប្រវ័ញ្ចប្រាក់ខែពីសំណាកនិយោជក។ ដូចនេះហើយទើបច្បាប់ការងារបង្កើតឡើងដោយមានកំណត់នូវប្រាក់ឈ្នួលអប្បបរមា ដើម្បីការពារកម្មករនិយោជិតឲ្យជៀសពីការទទួលប្រាក់ខែទាបជាងច្បាប់កំណត់ ព្រមទាំងកំណត់ពីដែនកំណត់សិទ្ធិរបស់និយោជក និង និយោជិត។ មិនតែប៉ុណ្ណោះ ការសិក្សាប្រធានបទនេះក៏ដើម្បីស្វែងយល់បន្ថែមឲ្យកាន់តែច្បាស់អំពីប្រភេទនៃប្រាក់ឈ្នួល និងកត្តាណាខ្លះដែលធ្វើឲ្យប្រាក់ឈ្នួលយើងទាបដោយមិនគ្រប់គ្រាន់ក្នុងការបំពេញតម្រូវការប្រចាំថ្ងៃ។

ទន្ទឹមនឹងនេះដែរ ការកំណត់ប្រាក់ឈ្នួលនៅកម្ពុជាគឺអាស្រ័យទៅលើកត្តា ២ សំខាន់ៗគឺ កត្តាសង្គម និង កត្តាសេដ្ឋកិច្ច ដោយកត្តាសង្គមគឺគេកំណត់ប្រាក់ឈ្នួលអប្បបរមាយ៉ាងណាឲ្យសមស្របទៅនឹងតម្រូវការចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ ដូចជាការចាយវាយសម្រាប់ម្ហូបអាហារ ការសិក្សារៀនសូត្រ ការចំនាយលើថ្លៃទឹកភ្លើង និងការចំនាយផ្សេងៗទៀត រីឯកត្តាសេដ្ឋកិច្ចគឺគេមើលទៅលើស្ថានភាពបច្ចុប្បន្ននៃប្រទេសនោះ ដោយប្រាក់ឈ្នួលការងារនឹងកើនឡើងប្រសិនបើសេដ្ឋកិច្ចជាតិរីកចម្រើន ក៏ប៉ុន្តែប្រសិនបើសេដ្ឋកិច្ចជាតិធ្លាក់ចុះ នោះនឹងធ្វើឲ្យប្រាក់ឈ្នួលការងារថយចុះដែរ។ ដោយ ឡែកតាមរយៈការស្រាវជ្រាវសង្កេតឃើញថាកំណើនប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារតែកំណើនផ្នែកសេដ្ឋកិច្ច បូករួមនឹងការឡើងថ្លៃសម្រាប់ការចំនាយប្រចាំថ្ងៃ។ ប៉ុន្តែថ្វីត្បិតតែប្រាក់ឈ្នួលកម្មករមានការកើនឡើងជាលំដាប់ក៏ដោយ

ក៏ប្រាក់ឈ្នួលកម្មករនៅប្រទេសកម្ពុជា យើងមានកម្រិតទាប និងមិនគ្រប់គ្រាន់សម្រាប់ការចំនាយបើធៀបទៅនឹងប្រទេសដទៃ ហើយកត្តាសំខាន់ៗដែលធ្វើឲ្យមានភាពមិនគ្រប់គ្រាន់នេះមានដូចជាកត្តាសុខភាព ការសិក្សា វិសមភាពក្នុងសង្គម សន្តិសុខសង្គម ការជួញដូរនិងលាំហូរហិរញ្ញវត្ថុ និង និរន្តរភាពសន្តិសុខសង្គម។

សរុបសេចក្តីមក ទោះបីជាតាមរយៈការស្រាវជ្រាវនេះឃើញនូវចំនុចខ្វះខាតជាច្រើនទាក់ទងនឹងកម្រិតប្រាក់ឈ្នួលនៅប្រទេសកម្ពុជា ដោយវាមានកម្រិតទាបខ្លាំងបើធៀបទៅនឹងប្រទេសដទៃ ហើយវាមិនគ្រប់គ្រាន់សម្រាប់ការចំនាយប្រចាំថ្ងៃរបស់កម្មករនិយោជិតក៏ដោយ ក៏យើងអាចរកឃើញពីមូលហេតុនៃភាពខ្វះខាតនេះ ហើយសិក្សាពីមូលហេតុនេះដើម្បីស្វែងរកនូវដំណោះស្រាយក៏ដូចជាវិធានការយ៉ាងណាដើម្បីលុបបំបាត់នូវភាពមិនគ្រប់គ្រាន់នៃប្រាក់ឈ្នួលនេះ និងជួយដល់កម្មករនិយោជិតដែលមានភាពខ្វះខាតក្នុងជីវភាពរស់នៅ។

# អនុសាសន៍

ក្រោយពីធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះរួចមក យើងទទួលបាននូវអនុសាសន៍សំខាន់ៗ និងល្អៗជាច្រើនទាក់ទិននឹងភាពមិនគ្រប់គ្រាន់នៃប្រាក់ឈ្នួល ដែលជាប្រយោជន៍ក្នុងការការពារកម្មករនិយោជិតដែលមានភាពខ្វះខាតក្នុងជីវភាពរស់នៅដោយសារតែមិនទទួលបានប្រាក់ឈ្នួលគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារ។ ម៉្យាងទៀត ការសិក្សាស្រាវជ្រាវអំពីភាពមិនគ្រប់គ្រាន់នៃប្រាក់ឈ្នួលនេះ ក៏ជាជំនួយក្នុងការស្វែងរកដំណោះស្រាយដល់កម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលទាបជាងច្បាប់កំណត់។

ដោយសារតែច្បាប់ការងារនៅប្រទេសកម្ពុជា បានបង្កើតឡើងដោយយកគំរូតាមច្បាប់ការងាររបស់ប្រទេសបារាំង និងវិសោធនកម្មខ្លះពីច្បាប់ចាស់ ដូចនេះហើយចំណុចមួយចំនួនទាក់ទងនឹងប្រាក់ឈ្នួលការងារពុំទាន់មានការពន្យល់ និងបកស្រាយច្បាស់លាស់នៅឡើយទេ ហើយក៏នៅភាពខ្វះខាតច្រើនដែលធ្វើឲ្យការអនុវត្តនៅមិនទាន់ពេញលេញនៅឡើយ។ ម៉្យាងទៀត ការ អនុវត្តច្បាប់ការងារនៅប្រទេសកម្ពុជាទៅលើការបើកប្រាក់ឈ្នួល គឺនៅមានវិសមភាពនៅឡើយ ដោយសារនៅក្នុងវិស័យការងារតាមគ្រឹះស្ថានមួយចំនួនឲ្យតម្លៃទៅលើកម្មករបរទេសជាងកម្មករខ្មែរបើទោះបីជាកម្មករខ្មែរមានសមត្ថភាពស្មើនឹងកម្មករបរទេសក៏ដោយ ក៏ម្ចាស់វិនិយោគទុនមួយចំនួនហាក់ដូចជាមិនមានទំនុកចិត្តលើកម្មករខ្មែរ ដោយសារឃើញថាអត្រាការសិក្សារបស់ប្រជាជនខ្មែរយើងមានកម្រិតទាប ហើយអត្រាមនុស្សដែលខ្វះជីវជាតិ និងលូតលាស់មិនសូវបានល្អខ្ពស់ជាពិសេសនៅតាមជនបទ បើធៀបទៅនឹងប្រទេសដទៃ ដែលធ្វើឲ្យអ្នកវិនិយោគមួយចំនួនយល់ថាកម្មករខ្មែរពុំសូវមានសុខភាពមាំទាំ។

ដោយសារតែមានគំនិតអវិជ្ជមានពីសំណាកអ្នកវិនិយោគបរទេសទៅលើសមត្ថភាពកម្មករខ្មែរច្រើន ដែលជាហេតុធ្វើឲ្យកម្មករខ្មែរទទួលបាននូវប្រាក់ឈ្នួលមិនគ្រប់គ្រាន់ នោះរាជរដ្ឋាភិបាលព្រមទាំងប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតែចូលរួមទាំងអស់គ្នាធ្វើការប្រែ រកដំណោះស្រាយធ្វើយ៉ាងណាដើម្បីធ្វើឲ្យសេដ្ឋកិច្ចជាតិរីកចម្រើន ដែលជម្រុញឲ្យលុបបំបាត់នូវភាពមិនគ្រប់គ្រាន់នៃប្រាក់ឈ្នួលរបស់កម្មករនិយោជិត។

ដំណោះស្រាយដើម្បីលុបបំបាត់ភាពមិនគ្រប់គ្រាន់នៃប្រាក់ឈ្នួលមានដូចខាងក្រោម៖

- រាជរដ្ឋាភិបាលត្រូវពង្រឹងឡើងវិញទៅលើវិស័យអប់រំ ក៏ដូចជាគ្រឹះស្ថានសិក្សាទាំងនៅទីក្រុង និងនៅតាមបណ្តាខេត្ត ជាពិសេសគឺនៅតាមជនបទដែលដាច់ស្រយាល ឆ្ងាយពីទីក្រុង ដោយធ្វើយ៉ាងណាផ្តល់មធ្យោបាយងាយស្រួលដល់ពួកគេដើម្បីទៅ សាលារៀនសិក្សារៀនសូត្រ ដូចជាបង្កើតសាលារៀនឲ្យច្រើននៅតាមទីជនបទ ព្រមទាំងបញ្ជូនគ្រូដែលមានគរុកោសល្យ និងមានសមត្ថភាពខ្ពស់ទៅបង្រៀន។ ម៉្យាងទៀត នៅតាមបណ្តាសាលារដ្ឋគួរតែបន្ថែមនូវកន្លែងពិសោធន៍ស្រាវជ្រាវ ដូចនៅសាលាឯកជនដែរ ដើម្បីឲ្យសិស្សានុសិស្សដែលសិក្សានៅ សាលារដ្ឋមានឱកាសបានពិសោធន៍ផ្ទាល់តាមអ្វីដែលពួកគេបានសិក្សា ដូចជាក្នុងមុខវិជ្ជាគីមីវិទ្យា ជាដើម។ ក្រៅពីភារកិច្ចរបស់រាជរដ្ឋាភិបាលហើយ ឪពុកម្តាយ ឬអាណាព្យាបាលរបស់ក្មេងត្រូវតែឲ្យពួកគេចូលរៀនដើម្បីទទួលយកនូវចំនេះដឹង ឲ្យបានច្រើន ដោយមិនត្រូវឲ្យពួកគេឈប់រៀនដើម្បីទៅធ្វើការរកស៊ីជួយរកចំនូលចូលគ្រួសារទាំងមិន ទាន់រៀនចប់នោះទេ។
- ប្រជាជនត្រូវតែសិក្សាស្វែងយល់ឲ្យបានច្រើនទាក់ទងនឹងរបបអាហារណាដែលមានជីវជាតិគ្រប់គ្រាន់ និង ល្អចំពោះសុខភាព ជាពិសេសនៅតាមជនបទ គឺរបបអាហាររបស់ពួកគេមិនសូវល្អ និងមានអនាម័យនោះទេ ដែលជាហេតុធ្វើឲ្យសុខភាព ចុះខ្សោយងាយរងជម្ងឺ ហើយប្រាជ្ញាមិនសូវវាងវៃ និងនាំឲ្យសមត្ថភាពការងារអន់ ថយ។ ដូចនេះ ប្រជាជនគ្រប់រូបគួរតែទទួលទាននូវអាហារណាដែលល្អសម្រាប់ សុខភាព និងរស់នៅឲ្យមានអនាម័យ ដើម្បីសុខភាពល្អមាំទាំ និងអាចបំពេញការងារបានល្អពេញកម្លាំង។
- រាជរដ្ឋាភិបាលត្រូវតែពង្រឹងបន្ថែមទាក់ទិននៅនឹងបញ្ហាសេដ្ឋកិច្ចសង្គម ដោយត្រូវលុបបំបាត់ ឬ កាត់បន្ថយឲ្យបានច្រើននូវករណីចោរកម្ម ឬ ករណីមនុស្សឃាតដែលបង្កនូវភាពអសន្តិសុខក្នុងសង្គម ធ្វើឲ្យអ្នកវិនិយោគមិនហ៊ានមកបណ្តាក់ទុន ភ្ញៀវទេសចរណ៍មិនហ៊ានមកកំសាន្ត ដែលជាហេតុធ្វើឲ្យសេដ្ឋកិច្ចធ្លាក់ចុះ ហើយប្រាក់ឈ្នួលកម្មករក៏ធ្លាក់ចុះដែរ។ ដូចនេះត្រូវតែដាក់ពិន័យឲ្យតឹងរឹងទៅលើជនប្រព្រឹត្ត

ណាមួយដែលបង្កនូវភាពអសន្តិសុខដល់សង្គម និង លុបបំបាត់ឲ្យបានច្រើននូវអត្រាមនុស្សឃាត និងចោរកម្មក្នុងសង្គម។

- រាជរដ្ឋាភិបាលត្រូវតែបណ្តុះបណ្តាលនូវកម្មករជំនាញឲ្យបានច្រើន ដោយសារតែប្រទេសកម្ពុជាយើងខ្វះនូវកម្មករជំនាញ នោះរដ្ឋត្រូវតែជំរុញឲ្យកម្មករទាំងអស់សិក្សាបន្ថែមឲ្យមានជំនាញខ្ពស់។
- រដ្ឋត្រូវតែបង្កើនការងារដល់កម្មករខ្មែរឲ្យបានច្រើន ដើម្បីឲ្យពួកគេមានការងារធ្វើ និង អាចផ្គត់ផ្គង់ជីវភាពបាន។

ជាចុងក្រោយចំពោះទស្សនៈវិស័យការងារនេះ រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ទៅលើផលប្រយោជន៍របស់កម្មករនិយោជិត ហើយត្រូវឲ្យតម្លៃទៅលើសមត្ថភាពការងាររបស់កម្មករខ្មែរព្រមទាំងស្តារប្រទេសជាតិយ៉ាងណាឲ្យមានការរីកចម្រើនខាងសេដ្ឋកិច្ចជាតិ និង មានសន្តិសុខសង្គមល្អ ដែលជាស្ពានធ្វើឲ្យកម្រិតប្រាក់ឈ្នួលរបស់កម្មករនិយោជិតក្នុងប្រទេសកើនឡើង។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។
- ព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១, ១០ មករា ១៩៩៧ ប្រកាសឲ្យប្រើប្រាស់ស្តីពីការងារ។
- សារាចរស្តីពីប្រាក់ឈ្នួលការងារយប់ចេញដោយក្រសួងការងារ, លេខ១៨៥ កប/សរ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧។
- ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសម្រាប់ឆ្នាំ២០១៩, លេខ៤៦៥ ក.ប/ប្រ.ក.ខ.ល, ០៥ តុលា ២០១៨។
- ប្រកាសស្តីពីការធ្វើការងារបន្ថែមម៉ោងក្រៅពីថិរវេលាធម្មតា, លេខ៨០ សកបយ, ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៩។
- សេចក្តីជូនដំណឹងលេខ០៤១/១១ ក.ប/ស/ជ.ណ អំពីការផ្តល់អត្ថប្រយោជន៍ផ្សេងដល់កម្មករនិយោជិត, ០៧ មីនា ២០១១ ។
- ប្រកាសស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល, លេខ២៤៨ កប/ប្រក, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤។
- ប្រកាសស្តីពីការឈប់សម្រាកពិសេស, លេខ២៦៧ សកបយ, ១៤ តុលា ២០០១។
- សេចក្តីប្រកាសពត៌មានស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និង ផលិតស្បែកជើងនៅកម្ពុជាឆ្នាំ២០១៥, ១២ វិច្ឆិកា ២០១៤។
- ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៧, ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦។
- សេចក្តីជូនដំណឹងលេខ ០៦ សកអ អំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ០៣ មីនា ឆ្នាំ១៩៩៧។
- សេចក្តីជូនដំណឹងលេខ ០១៧ សកបយ អំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ១៨ កក្កដា ឆ្នាំ២០០០។
- សេចក្តីជូនដំណឹងលេខ ៧៤៥ កកបវអំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ២៣ តុលា ឆ្នាំ២០០៦។

- សេចក្តីជូនដំណឹងលេខ ០៣២/០៨ កប/សជណ អំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ១៧ មេសា ឆ្នាំ២០០៨។
- សេចក្តីជូនដំណឹងលេខ ០៤៩/១០ កអ/សជណ អំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ០៩ កក្កដា ឆ្នាំ២០១០។
- សេចក្តីជូនដំណឹងលេខ ០៤១/១១ កប/សជណ អំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ០៧ មីនា ឆ្នាំ២០១១។
- សេចក្តីជូនដំណឹងលេខ ២០៦ កប/សជណ អំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ១៣ ធ្នូ ឆ្នាំ២០១១។
- សេចក្តីជូនដំណឹងលេខ ២៣០ កប/សជណ អំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ២៥ កក្កដា ឆ្នាំ២០១២។
- សេចក្តីជូនដំណឹងលេខ ១០៣ កប/សជណ អំពីប្រាក់ឈ្នួលសុទ្ធសាធអប្បបរមារបស់កម្មករនិយោជិត, ០៩ មេសា ឆ្នាំ២០១៣។
- ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និង ផលិតស្បែកជើង, លេខ៣១៧ កប/ប្រក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។
- ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និង ផលិតស្បែកជើងឆ្នាំ២០១៦, លេខ ៤០៩/១៥ កប/ប្រក, ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥។
- ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និង ផលិតស្បែកជើងឆ្នាំ២០១៨, លេខ ៣៩៦ កប/ប្រកខល, ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៧។
- ប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និង ផលិតស្បែកជើងឆ្នាំ២០១៩, លេខ ៤៦៥ កប/ប្រកខល, ចុះថ្ងៃទី ០៥ តុលា ឆ្នាំ២០១៨។

## សៀវភៅ


- ពុទ្ធសាសនបណ្ឌិត, ១៩៦៧. *វចនានុក្រមខ្មែរ*. ភ្នំពេញះកម្ពុជា។
- ហៃល ចំរើន, ២០០៥. *នីតិការងារ*. ភ្នំពេញះហ្វូណន។

- ដាញ៉ែល អាដល័រ និងផ្សេងទៀត, ២០០៥. *សៀវភៅណែនាំអំពីច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាសម្រាប់វិស័យកាត់ដេរ.* ភ្នំពេញះDESIGN GROUP។

**គេហទំព័រ**

- RFI សម្លេងពិភពលោក, "កម្មករកាន់តែច្រើនធ្វើការតវ៉ាតម្លើងប្រាក់ខែ១៦០ដុល្លារ", ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៣, http://km.rfi.fr/employee-demonstration-around-cambodia
- ខ្មែរ សារិកា,"ក្រុមសហជីពអាត់ ធន់ កំណត់ប្រាក់ឈ្នួល១៧៧ដុល្លារដល់កម្មករ", https://khmersahrika.com/2015/06/21/%e1%9e%80%e1%9f%92%e1%9e%9a%e1%9e%bb%e1%9e%98%e2%80%8b%e1%9e%9f%e1%9e%a0%e1%9e%87%e1%9e%b8%e1%9e%96%e2%80%8b%e1%9e%9b%e1%9f%84%e1%9e%80-%e1%9e%a2%e1%9e%b6%e1%9e%8f%e1%9f%8b-%e1%9e%92%e1%9e%93%e1%9f%8b/
- "ទំព័រស្តីពីប្រទេសកម្ពុជានិងសូចនាករសំខាន់ៗ", https://www.worldbank.org/content/dam/Worldbank/document/EAP/cambodia/Cambodia_EAP_Update-Oct2014_KH.pdf
- OECD, "Structural Policy Country Notes Cambodia" [គោលនយោបាយតម្លាភាពប្រទេសកម្ពុជា], https://www.oecd.org/site/seao/Cambodia.pdf
- World Bank, "Recent Economic Developments and Outlook" [ការអភិវឌ្ឍសេដ្ឋកិច្ចនិងទស្សនវិស័យថ្មីៗ], https://www.worldbank.org/en/country/cambodia/publication/cambodia-economic-update-october-2018-recent-economic-developments-and-outlook
- ILO, "Minimum Wages in the Global Garment Industry" [ប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសកល] https://www.ilo.org/asia/info/research-and-data/WCMS_317002/lang--en/index.htm
- UNDP, "Human Development Indicators in Cambodia" [សូចនាករអភិវឌ្ឍមនុស្សនៅកម្ពុជា], http://hdr.undp.org/en/countries/profiles/KHM
- Antoine, "Inequality in Education" [វិសមភាពនៅក្នុងវិស័យសិក្សា], https://inequalityproject.wordpress.com/inequality-in-

education/?fbclid=IwAR0_4I5dZo518-6gvqhaCqQBKTtdoGZ4y4wIuFC5foLmedekVLmBtGvVyM4

- UNDP, "Human Development Indicators in Cambodia" [សូចនាករអភិវឌ្ឍមនុស្សនៅកម្ពុជា], http://hdr.undp.org/en/countries/profiles/KHM
- UNDP, "Human Development Indicators in South Korea " [សូចនាករអភិវឌ្ឍមនុស្សនៅកូរ៉េខាងត្បូង], http://hdr.undp.org/en/countries/profiles/KOR
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, "ការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា", http://www.mlvt.gov.kh/index.php?option=com_k2&view=item&id=644%3A%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%80%E1%9F%86%E1%9E%8E%E1%9E%8F%E1%9F%8B%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%B

# ឧបសម្ព័ន្ធ

# ច្បាប់រដ្ឋធម្មនុញ្ញ

# ច្បាប់ការងារ

# លិខិតបទដ្ឋានគតិយុត្ត

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈនិយោជក អង្គការជាតិ និងអន្តរជាតិទាំងអស់ឱ្យបានជ្រាបថា ក្នុងឆ្នាំ២០១៧ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តសហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ក្នុងការពង្រឹងយន្តការ នីតិវិធី និងលើកកម្ពស់ការយល់ដឹងអំពីលក្ខណវិនិច្ឆ័យទាំង៧ នៃការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា។

ទន្ទឹមនឹងនេះ គណៈកម្មការប្រឹក្សាការងារក៏បានបន្តបង្កើតឱ្យមានក្រុមការងារបច្ចេកទេសត្រីភាគីដែលមានតំណាងភាគីនិយោជកចំនួន១៦រូប តំណាងភាគីកម្មករនិយោជិតចំនួន១៦រូប និងតំណាងភាគីរាជរដ្ឋាភិបាលចំនួន១៦រូប ដើម្បីពិភាក្សាលម្អិតអំពីបម្រែបម្រួលលក្ខណវិនិច្ឆ័យទាំង៧ ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៨។ បន្ទាប់ពីកិច្ចប្រជុំចំនួន៣ថ្ងៃ ចាប់ពីថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧ ដែលស្មើនឹង៤លើក ក្រុមការងារបច្ចេកទេសត្រីភាគី បានបង្រួមគម្លាតនៃតួលេខរៀងខ្លួន និងបានលើកយកតួលេខ ១៧០ដុល្លារអាមេរិក ដែលជាសំឡេងឯកច្ឆន្ទរបស់ភាគីតំណាងកម្មករនិយោជិត តួលេខ ១៦២ដុល្លារអាមេរិក ដែលជាសំឡេងឯកច្ឆន្ទរបស់ភាគីតំណាងនិយោជក និងតួលេខ ១៦៥ដុល្លារអាមេរិក ដែលជាសំឡេងឯកច្ឆន្ទរបស់ភាគីតំណាងរាជរដ្ឋាភិបាល ដើម្បីដាក់ជូនគណៈកម្មការប្រឹក្សាការងារប្រជុំពិភាក្សាបន្ត។

នៅរសៀលថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ គណៈកម្មការប្រឹក្សាការងារបានបើកកិច្ចប្រជុំអាណត្តិទី៨ លើកទី១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបន្តពិនិត្យនិងពិភាក្សាលើលទ្ធផលរបស់ក្រុមការងារបច្ចេកទេសត្រីភាគី និងធ្វើការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨។ ក្រោយការពិភាក្សា ភាគីទាំងអស់បានគាំទ្រជាឯកច្ឆន្ទលើតួលេខ ១៦៥ ដុល្លារអាមេរិក។

ដូច្នេះ គណៈកម្មការប្រឹក្សាការងារបានស្នើតួលេខចំនួន ១៦៥(មួយរយហុកសិបប្រាំ) ដុល្លារអាមេរិក ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការពិនិត្យ និងសម្រេចលើប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨។

យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែយកចិត្តទុកដាក់អំពីសុខុមាលភាព



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

និងជីវភាពរស់នៅសមរម្យរបស់កម្មករនិយោជិត និងផលិតភាពរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន បានសម្រេចបន្ថែមទឹកប្រាក់ចំនួន ៥(ប្រាំ) ដុល្លារអាមេរិក លើទឹកប្រាក់ចំនួន ១៦៥(មួយរយហុកសិបប្រាំ) ដុល្លារអាមេរិក។ ដូច្នេះ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨ មានចំនួន ១៧០ (មួយរយចិតសិប) ដុល្លារអាមេរិក ក្នុងមួយខែ ដោយអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

ទន្ទឹមនឹងនេះ ប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ដែលកម្មករនិយោជិតធ្លាប់ទទួលបានកន្លងមក ត្រូវបានរក្សាទុកនៅដដែល មានដូចជា ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ៧ដុល្លារអាមេរិក ក្នុងមួយខែ ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ដុល្លារអាមេរិក ក្នុងមួយខែ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយស្ម័គ្រចិត្តចំនួន ២ ០០០រៀលក្នុងមួយថ្ងៃ ឬទទួលបានបាយមួយពេលដោយឥតគិតថ្លៃ និងប្រាក់រង្វាន់អតីតភាពការងារចំនួនពី ២ដុល្លារអាមេរិក ដល់ ១១ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតដែលបានធ្វើការចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី១១។ ដូចនេះ ជាមធ្យមកម្មករនិយោជិតម្នាក់ នឹងទទួលបានប្រាក់បៀវត្សយ៉ាងតិចចំនួនពី ១៨៧ដុល្លារអាមេរិក ដល់ ១៩៨ដុល្លារអាមេរិកក្នុងមួយខែ។

ដើម្បីជួយសម្រួលបន្ទុកចំណាយរបស់និយោជក រាជរដ្ឋាភិបាលនឹងៈ

១- ពន្យារសុពលភាពការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញរបស់រោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងកាបូប សម្រាប់រយៈពេល៥ឆ្នាំ (ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២)។

២- លុបកម្រៃគ្រប់គ្រងការនាំចេញ (Export Management Fee) នៅក្រសួងពាណិជ្ជកម្ម។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចផ្តល់ប្រាក់បន្ថែមចំនួន ៥(ប្រាំ) ដុល្លារអាមេរិក លើការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៨ នេះ ដែលរួមចំណែកធ្វើឱ្យស្ថានភាពជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង កាន់តែមានភាពល្អប្រសើរឡើងជាងមុន ហើយក៏ជាកត្តាដ៏សំខាន់ក្នុងការជំរុញផលិតភាពផងដែរ។

ក្រសួងក៏សូមថ្លែងអំណរគុណដល់អង្គការអន្តរជាតិខាងការងារ (ILO) ដែលបានផ្តល់នូវកិច្ចសហការដ៏ជិតស្និទ្ធដល់ក្រសួងក្នុងការពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា។ ជាមួយគ្នានេះដែរ ក្រសួងក៏សូមថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហាប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និយោជក អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧